# ប្រវត្តិពុទ្ធសាសនា

## ក្រោយ

# ព្រះពុទ្ធបរិនិព្វាន

ដោយ

ព្រះគ្រូឃោសាធិរត៌ ឈាស់-ឡាយ

វត្តមហាមន្ត្រី ភ្នំពេញ

ព.ស. ២៥០៨

ចែកជាធម្មទាន

# ប្រវត្តិពុទ្ធសាសនា

ក្រោយ

# ព្រះពុទ្ធបរិនិព្វាន

ដោយ

## ព្រះគ្រូឃោសាភិរតំ លាស់~ឡាយ

ចតុមុខមហាមន្ត្រី ភ្នំពេញ
ព.ស. ២៥០៨

ចែកជាធម្មទាន

# ចំណាប់អារម្មណ៍

ក្នុងនាមខ្ញុំព្រះករុណា យើងខ្ញុំទាំងអស់គ្នាជាគ្រូសិស្សពុទ្ធិកមធ្យមសិក្សាវត្តគ្រូកោសល្យជំនាន់ទី៥ ឆ្នាំសិក្សា ព.ស.២៥៥២,គ.ស.២០០៨។ មានការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះឯកសារ "ប្រវត្តិពុទ្ធសាសនា ក្រោយព្រះពុទ្ធបរិនិព្វាន" ដែលបានរៀបរៀងដោយសម្តេចព្រះធម្មលិខិត **ឈាស់ ឡាយ** សម្តេចព្រះសង្ឃនាយករងទី១ នៃព្រះរាជាណាចក្រកម្ពុជា កាលព្រះអង្គនៅព្រះឋានៈជាព្រះគ្រូឃោសាគិរីគង់នៅវត្តមហាមន្ត្រី ក្រុង ភ្នំពេញ ក្នុង ព.ស. ២៥០៨ ។ ឯកសារនេះបានយកមកបង្រៀនដល់គ្រូសិស្សពុទ្ធិកមធ្យមសិក្សាជំនាន់ទី៥ ដោយលោកសាស្ត្រាចារ្យ **ឆេត ផុន** ។

ខ្ញុំព្រះករុណា យើងខ្ញុំទាំងអស់គ្នាយល់ឃើញថា ឯកសារប្រវត្តិពុទ្ធសាសនាក្រោយព្រះពុទ្ធបរិនិព្វាននេះ មានសារប្រយោជន៍ធំធេងណាស់ ព្រោះជាឯកសារមួយដ៏សំខាន់បំផុតរបស់ពុទ្ធសាសនា សម្រាប់ជាប្រយោជន៍ដល់អ្នកសិក្សារៀនសូត្រ ដើម្បីស្វែងយល់ឲ្យបានស៊ីជម្រៅ។ តែជាអកុសល ដោយឯកសារនេះចាស់យូរពេក អក្សរលប់មើលមិនច្បាស់ មានកន្លែងខ្លះទំព័រសារស៊ើមើលមិនរួច ។ ដោយការពេញចិត្តពេញថ្លើម ខ្ញុំព្រះករុណា **ឆិញ សៅ** ព្រមទាំងគ្រូសិស្សទាំងអស់ក៏ពិគ្រោះគ្នា រួចក៏បានសម្រេចឯកភាពគ្នាជាមួយលោកគ្រូ **ឆេត ផុន** ជាទីងយកឯកសារមិនច្បាស់នេះទៅវាយកុំព្យូទ័រឡើងវិញ។ បន្ទាប់មក ខ្ញុំព្រះករុណាទាំងពីររូបមានលោកសាស្ត្រាចារ្យ **ឆេត ផុន** និងខ្ញុំព្រះករុណា **ឆិញ សៅ** ជាតំណាងឲ្យគ្រូសិស្សចូលមកក្រាបបង្គំទូលថ្វាយសម្តេចព្រះធម្មលិខិតសុំការអនុគ្រោះយល់ព្រមផង និងបានសាកសួរអំពីចំណុចខ្លះៗមួយចំនួនពីសម្តេចផង ដើម្បីបានបោះពុម្ពជាថ្មីអោយបានល្អត្រឹមត្រូវ ងាយស្រួលដល់អ្នកសិក្សារៀនសូត្រជំនាន់ក្រោយ ។ ក្នុងពេលនោះ សម្តេចព្រះធម្មលិខិត ទ្រង់ក៏បានអនុញ្ញាតតាមការស្នើសុំ ដោយព្រះអង្គមានទឹកព្រះទ័យត្រេកអររីករាយបំផុត ។ ថ្ងៃនោះ ខ្ញុំព្រះករុណាទាំងពីររូបក៏ទៅសុំព្រះយោបល់អំពី សម្តេចព្រះមហាអរិយវង្ស

សៅរ៍ ចន្ទមុនី ព្រះអគ្គាធិការរង និងជាព្រះលេខាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ដើម្បីពិភាក្សាក្នុងការបោះពុម្ពសៀវភៅ "ប្រវត្តិពុទ្ធសាសនាក្រោយព្រះពុទ្ធបរិនិព្វាន" នេះ ។

ក្រោយពីសម្តេចព្រះមហាអរិយវង្ស សៅរ៍ ចន្ទមុនី បានផ្តល់ព្រះយោបល់ និងពិនិត្យផ្ទៀងផ្ទាត់ឲ្យត្រូវទៅតាមអក្ខរាវិរុទ្ធរួចហើយ, ខ្ញុំព្រះករុណា ឆិញ សៅ ក៏បានទៅជួបមហាឧបាសិកា សុខ អ៊ីម ដើម្បីស្នើសុំជួយបោះពុម្ពសៀវភៅនេះឡើងវិញ. មហាឧបាសិកា សុខ អ៊ីម ក៏មានសទ្ធាជ្រះថ្លាជួយបោះពុម្ពចំនួន ១.០០០ ក្បាល ព្រមទាំងឯកឧត្តមបណ្ឌិត គុណ ឆេង និងលោកជំទាវ និងសមណសិស្ស-និស្សិត ពុទ្ធបរិស័ទគ្រប់រូបបានរួមចំណែកជួយបោះពុម្ពសៀវភៅនេះមួយចំនួនទៀតផងដែរ ។

សូមក្រាបបង្គំទូលថ្វាយ និងថ្វាយព្រះពរចំពោះសម្តេចព្រះធម្មលិខិត សូមសម្តេចមានព្រះសុខភាពល្អបរិបូណ៌ និងព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីបានជាម្លប់ដ៏ត្រជាក់ត្រជុំដល់ពុទ្ធបរិស័ទ និងព្រះសង្ឃទូទៅ ។

សូមតេជានុភាព និងបារមីនៃព្រះពុទ្ធសាសនា បានផ្សព្វផ្សាយទូទៅពេញសាកលលោក ។

ភ្នំពេញ, ៤ ១៥ ៧ ឆ្នាំជូត សំរឹទ្ធិស័ក ព.ស. ២៥៥២ / គ.ស. ២០០៨

ភិក្ខុធម្មរក្ខិតោ ឆិញ សៅ

តំណាងគរុសិស្សពុទ្ធិកមធ្យមសិក្សាជំនាន់ទី៤

បានឃើញ និងយល់ព្រម

វត្តសន្សំកុសល ភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ព.ស. ២៥៥២ / គ.ស. ២០០៨

សម្តេចព្រះធម្មលិខិត ឡោះ ឡាយ

សម្តេចព្រះសង្ឃនាយករងទី១ នៃព្រះរាជាណាចក្រកម្ពុជា

## អារម្ភបទ

អត្ថបទ-ចំពូកនៃសេចក្តីអត្ថាធិប្បាយក្នុងសៀវភៅនេះ ខ្ញុំឲ្យឈ្មោះ ៧ ប្រវត្តិពុទ្ធសាសនាក្រោយព្រះពុទ្ធបរិនិព្វាន, ព្រោះសាច់រឿងជាប់ទាក់ទងនឹងពុទ្ធសាសនា ក្រោយព្រះពុទ្ធបរិនិព្វានដោយច្រើន ។

ការប្រព្រឹត្តទៅឬរីកសាយនៃព្រះពុទ្ធសាសនាមិនមានជោគវាសនា ត្រឹមតែធម៌វិន័យនោះទេ ប៉ុន្តែការពិសេសបំផុតគឺមនុស្ស, មនុស្សអ្នកបញ្ញត្តសាសនា, មនុស្សអ្នកប្រតិបត្តិ និងពង្រីកសាសនាឲ្យមានធម្មស្មើគ្រប់ទិសទី ។

បើគេក្រឡេកមើលតាមតំបន់ឬទ្វីបនីមួយៗនោះ គេឃើញគោលចារឹកនៃពុទ្ធសាសនាចាក់គ្រឹះមាំតែក្នុងជម្ពូទ្វីបទេ ក្នុងសម័យពុទ្ធកាល ហើយមិនបានប្រព្រឹត្តទៅសព្វទីតំបន់ផង គឺសម័យពុទ្ធកាល ពុទ្ធសាសនាផ្សាយអានុភាពក្នុងជម្ពូទ្វីប តែក្នុងឥណ្ឌាខាងជើងទេ ហើយបានតែ៧រដ្ឋប៉ុណ្ណោះគឺ :

១-រដ្ឋកាសី និងកោសល (ក្រុងពារាណសី និងសាវត្ថី),

២-រដ្ឋមគធៈ និងអង្គៈ (ក្រុងរាជគ្រឹះ និងចម្បា),

៣-សក្ករដ្ឋ (ក្រុងកបិលពស្តុ),

៤-វជ្ជីរដ្ឋ (ក្រុងវេសាលី),

៥-មល្លរដ្ឋ (ក្រុងបាវាឬកុសិនារា),

៦-វង្សរដ្ឋ (ក្រុងកោសម្ពី),

៧-កុរុរដ្ឋ (ក្រុងឥន្ទបត្រ) ។

លុះសម័យក្រោយធ្វើសង្គាយនារួច ទើបពុទ្ធសាសនាក៏ទំពង្រីកនូវអានុភាពរបស់ខ្លួនឲ្យរីកលូតចូលទៅក្នុងរដ្ឋថ្មីៗនាជម្ពូទ្វីបនេះទៀត, ដូចជារដ្ឋ

កស្មីរ និងគន្ធារ(សាគល និងបាគីស្ថាន), រដ្ឋមហិសកមណ្ឌល(ម៉ៃសោរ៍) រដ្ឋវនវាសី(កនរ), រដ្ឋអបរន្តកៈ(គុជរ៉ាតខាងជើង និងកច្ឆាកាវ៍-សិន្ធុ), មហារដ្ឋ(ឥណ្ឌាកណ្ដាល), រដ្ឋយោនកៈ(អាហ្វហ្គានិស្ថាន), តំបន់ហេមពាន និងសុវណ្ណភូមិ (ក្បែរភ្នំហិមាលយា និងស្រុកមន) ។

កាលដែលធ្វើតតិយសង្គាយនារួចនោះ ពុទ្ធសាសនាមិនត្រឹមតែបានផ្សាយទូវធម្មរស្មីទៅក្នុងរដ្ឋ និងតំបន់នាជម្ពូទ្វីបនេះប៉ុណ្ណោះទេ ថែមទាំងសោតអណ្ដែតទៅប្រតិស្ឋានចាក់ឫសជាប់ក្នុងលង្កាទ្វីបទៀតផង ។

សម័យក្រោយពុទ្ធកាលនោះ ពុទ្ធសាសនាបានរីកលូតលាស់ទៅក្នុងទិសទីច្រើនកន្លែងក៏ពិតមែន ប៉ុន្តែមិនទាន់ប្រាកដជាមានជំហររឹងប៉ឹងនៅឡើយ ទេ ព្រោះធម្មវិន័យនៅចេះតែក្នុងមាត់ព្រះសង្ឃ និងមនុស្សម្នាក់ៗ មិនទាន់បានចារជាក់ក្នុងក្បួនច្បាប់ជាសាធារណៈអោយជាប់ជាស្ថាពរនៅឡើយ ម្ល៉ោះហើយពុទ្ធបរិស័ទចេះតែមានយោបល់បែកបាក់គ្នាជាច្រើនលើក ។

អាស្រ័យហេតុបែបនេះហើយ បានជាក្នុង ព.ស. ៤៤៣ ឆ្នាំ នោះ គេឃើញព្រះសង្ឃលង្កាចារធម្មវិន័យនោះជាក់ក្នុងគម្ពីរ តែចារជាសីហលភាសា (ភាសាដែលវិជ័យកុមារជាបុត្រសីហពាហុនាំពីសីហបុរី មកប្រើក្នុងលង្កាទ្វីប គឺភាសាជូ ភូមិ) ។

តមកដោយលោកយល់ឃើញថា : ធម្មវិន័យដែលផុះជាប់ជាមួយនឹងសីហលភាសានោះ មិនសម្រេចប្រយោជន៍គ្រប់ជាតិសាសន៍បានទេ, ដូចនេះបានជាក្នុង ព.ស. ៩៥៦ ពុទ្ធឃោសកិច្ចគឺព្រះពុទ្ធឃោសាចារ្យទៅប្រែធម្មវិន័យចេញពីសីហលភាសានោះ មកជាមគធភាសា (ភាសាអ្នកមគធៈដែលគេប្រើពីសម័យពុទ្ធកាលគឺភាសាបាលី) វិញ ។

គួរឆ្ងល់ថា : ចុះកាលធ្វើសង្គាយនារួចថ្មីៗទាំងប៉ុន្មានលើកនោះ ម្ដេចក៏ព្រះសង្ឃក្នុងជម្ពូទ្វីបមិនបានចារដាក់ក្នុងស្លឹករឹតទៅ ? ឬក៏សម័យនោះមិនមានអក្សរ ?

ថា : មិនមែនមិនមានអក្សរនោះទេ ប៉ុន្តែប្រហែលជាឱកាសមិនទាន់អនុញ្ញាតឲ្យហើយមើល ! បានជាព្រះអរហន្តទាំងឡាយសុខចិត្តបៀមទុកនូវធម្មវិន័យតែក្នុងមាត់ជាមុខបាឋតៗគ្នាមកនោះ ។

សំណុំរឿងដែលខ្ញុំសរសេរមកនេះ គ្រាន់តែជាប្រវត្តិមួយសម្រាប់ទុកជាឯកសារនៃការចេះដឹងបន្ទាប់បន្សំប៉ុណ្ណោះ. ប៉ុន្តែបើបែរមកសរសេរអំពីហេតុការណ៍នៃការប្រែសម្រួលនូវអត្ថបទនេះវិញ នោះសាធុជនទាំងឡាយមុខជានឹកឆ្ងល់ខ្លះថា : ចុះអត្ថបទនេះលោកអ្នកសរសេរមានទស្សនៈនិងប្រែចេញពីគម្ពីរណាមក ?

សូមជ្រាបថា : ខ្ញុំអ្នកសរសេរមានទស្សនៈត្រឹមតែចង់ចេះដឹងខ្លួនឯងប៉ុណ្ណោះ ហើយក៏មានវត្ថុបំណងចង់ឲ្យសាធុជនយល់នូវប្រវត្តិ និងតម្លៃនៃពុទ្ធសាសនាផងដែរ, សោតឯអត្ថបទនេះវិញនោះ ខ្ញុំបានប្រែសង្ខេបអំពីគម្ពីរសមន្តបាសាទិកាអដ្ឋកថាវិន័យព្រមទាំងដីកាត្រង់ពាហិរនិទាន និងគម្ពីរវិសុទ្ធិមគ្គត្រង់ពុទ្ធឃោសប្បវត្តិព្រមទាំងរតនពិម្ពវង្សខ្លះដែរ, តែភាគច្រើនបំផុតគឺគម្ពីរមហាវង្សខុទ្ទកនិកាយព្រមទាំងដីកា ទោះជាសេចក្ដីយោងក៏ដោយ ។

ឯនិក្ខេបបទក្នុងសៀវភៅនេះមានពីរផ្នែកគឺ :

ក-ផ្នែកខាងជម្ពូទ្វីប, ខ-ផ្នែកខាងលង្កាទ្វីប ។

### ផ្នែកខាងជម្ពូទ្វីបមាន ៧ ចំពូកគឺ :

១-បឋមសង្គាយនា ទំព័រ២
២-ទុតិយសង្គាយនា " ៣
៣-ឧត្តិយវង្សក្រុងរាជគ្រឹះក្រោយពុទ្ធបរិនិព្វាន " ៧
៤-ប្រវត្តិរបស់ព្រះបាទអសោក " ១០
៥-បុញ្ញានុភាពរបស់ព្រះនាងអសន្ធិមិត្តា " ១៦
៦-សេចក្តីជ្រះថ្លារបស់ព្រះបាទអសោក " ២២
៧-តតិយសង្គាយនា " ២៩

### ផ្នែកខាងលង្កាទ្វីបមាន ៦ ចំពូកគឺ :

១-លង្កាទីបប្បវត្តិ និងពុទ្ធដំណើរ ទំព័រ ៣៤
២-ឧត្តិយវង្សក្នុងលង្កាទ្វីប " ៣៩
៣-ធាតុនិធាន និងពុទ្ធសាសនារបស់ព្រះគោតម " ៤៥
៤-ការចារឹកពុទ្ធវចនៈជាតួអក្សរ " ៦១
៥-អ្នកចម្លងគម្ពីរពីលង្កាមកវិញ " ៦២
៦-អ្នកចម្លងគម្ពីរនេះបន្តទៀត " ៦៦

ខ្ញុំយល់ថា : ចំពូកនៃនិក្ខេបបទទាំងប៉ុន្មាននេះ មុខជាមានហិតប្រយោជន៍ចំពោះពុទ្ធសាសនិកមិនខាន បើមិនច្រើនក៏គង់ជាជំនួយដល់ស្មារតីដែរ, ព្រោះប្រវត្តិនេះជាមគ្គុទេសក៍វិជ្ជាខាងពុទ្ធសាសនាសុទ្ធ ហើយជាគតិមួយសម្រាប់ពន្យល់ខួរឲ្យចេះដឹងនូវការអភិវឌ្ឍនៃពុទ្ធសាសនា ក្នុងតំបន់នៃទ្វីបរបស់មនុស្សតាមកាលៈទេសៈផង ។

**តិដ្ឋតុ សាសនំ ចិរំ**

**បជាសាយំ សមិជ្ឈតុ**

**លោកោ សន្តិញ្ច បប្បោតុ**

**និទ្ទុក្ខា ហោតុ សាបជា ៕**

*សូមឲ្យការប្រព្រឹត្តទៅនៃពុទ្ធសាសនាឋិតនៅអស់កាលដ៏យូរ,*
*សូមឲ្យក្តីប្រាថ្នារបស់មនុស្សលោកនេះបានសម្រេច,*
*សូមឲ្យមនុស្សលោកបានដល់នូវសន្តិសុខ,*
*សូមឲ្យពួកមនុស្សសត្វចៀសផុតនូវក្តីទុក្ខក្រៀមក្រំ ។*

**ព្រះគ្រូឃោសាគិរិត**

**ឈាស់-ឡាយ**

វត្តមហាមន្ត្រី ភ្នំពេញ,

ថ្ងៃ ៥ ៗ ៧ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥០៨
១០

## បណាមគាថា

**សេដ្ឋន្តិលោកតំ ពុទ្ធំ ធម្មំ សំឃំ អនុត្តរំ**
**ចន្ទិយ សាសនស្សេច បចត្តិញ្ញ សមាសតោ**
**ពុទ្ធកាលា បច្ឆាភាគេ សំខេបេន គថេមិហន្តិ**

សូមថ្វាយបង្គំចំពោះព្រះពុទ្ធជាអគ្គបណ្ឌិតប្រសើរផុតក្នុងត្រៃលោក ព្រមទាំងព្រះធម៌ និងព្រះសង្ឃមានគុណឥតអ្វីផ្ទឹមបាន, រួចហើយសូមសម្តែងនូវប្រវត្តិនៃពុទ្ធសាសនា ក្រោយពុទ្ធកាលដោយសេចក្តីរួមសង្ខេបដូចតទៅ ។

## ប្រវត្តិពុទ្ធសាសនា

ពាក្យស្តីប្រដៅរបស់អ្នកប្រាជ្ញម្នាក់ (ព្រះពុទ្ធ) ឬពាក្យទូន្មានប្រដៅរបស់អ្នកប្រាជ្ញទាំងឡាយ (សាវកពុទ្ធ) ហៅថា ពុទ្ធសាសនា ។

ការពង្រីកឬផ្សាយព្រោចនូវធម្មស្មើរបស់អ្នកប្រាជ្ញទាំងនោះ ទៅក្នុងទិសទីផ្សេងៗនៅលើសាកលលោកហៅថា ប្រវត្តិពុទ្ធសាសនា ។

ព្រះពុទ្ធ និងសាវកពុទ្ធបានស្រាវជ្រាវរួមគ្នា ហើយរកឃើញពិតនូវសច្ចធម៌នោះៗ ទើបបញ្ញត្ត និងសម្តែងពន្យល់ដល់ពុទ្ធបរិស័ទ ហើយតែងគោរពនូវសច្ចធម៌ដែលទ្រង់បញ្ញត្ត និងសម្តែងហើយនោះមុនគេផង ។

ដូចនេះហើយបានជាពុទ្ធបរិស័ទលើកយកនូវកិត្តិគុណទាំង ៣ របស់ពុទ្ធសាសនាគឺ ព្រះពុទ្ធ១ ព្រះធម៌១ ព្រះសង្ឃ១ មកតំកល់ទុកជាត្រៃបាវចនាសម្រាប់ជាសក្ខីភាពឬជាគោលល័ក្ខឋាននៃពុទ្ធសាសនា ទុកជាសរណដ្ឋានតរៀងមក ។

# ប្រវត្តិពុទ្ធសាសនវិភាគ

ប្រវត្តិពុទ្ធសាសនានេះ បើចែកតាមទីបមានពីរផ្នែកគឺ : ១-ផ្នែកខាងជម្ពូទីប, ២-ផ្នែកខាងលង្កាទីប ។

## ក-ប្រវត្តិពុទ្ធសាសនាខាងជម្ពូទីប

### ១-បឋមសង្គាយនា

ប្រវត្តិពុទ្ធសាសនាក្រោយព្រះពុទ្ធនិព្វានទោះ មិនសូវមានជំហររឹងប៉ឹងជាឯកភាពទេ ចេះតែមានការណ៍រកាំរកូសរវាងពុទ្ធបរិស័ទមិនស្របយោ-បល់គ្នាដោយលើកៗ ។

ហេតុនោះបានជាក្នុងពេលព្រះពុទ្ធនិព្វានបាន ៤ ខែ គេឃើញព្រះមហាកស្សបត្ថេរជាប្រធានគណៈសង្ឃចំនួន ៥០០ រូប សន្និបាតក្នុងសត្តប-ណ្ណគុហាក្បែរភ្នំវេភារៈដែនមគធៈជិតក្រុងរាជគ្រឹះ, ប្រជុំគ្នាសើរើទូវវិន័យ និងធម៌មកចោទ-ឆ្លើយ សូត្រសាជាថ្មីឡើងវិញប្រគេនព្រះសង្ឃស្តាប់ ហៅថាសង្គាយនា លុះចប់មួងៗ ព្រះសង្ឃទាំងអស់ដែលគង់ចាំស្តាប់ក៏សូត្រឡើងទាំងអស់ត្រឹមធេងជារបៀបមួយ ហៅថា អានត្រៃ ។

មកពីសុភទ្ទភិក្ខុមានយោបល់ជំទាស់ចំពោះពុទ្ធសាសនានោះហើយ បានជាព្រះមហាកស្សប, ឧបាលី, អានន្ទ ធ្វើបឋមសង្គាយនានេះ ដោយមានព្រះបាទអជាតសត្តុជាអ្នកឧបត្ថម្ភក៏ផង បឋមសង្គាយនានេះធ្វើ៧ខែទើបចប់។

### ២-ទុតិយសង្គាយនា

ក្រោយពីនោះមកអស់រយៈកាលត្រឹមតែ ១០០ ឆ្នាំ ប៉ុណ្ណោះ អព្ទុទហេតុដ៏ចង្រៃមួយទៀត ក៏បណ្តាលកើតឡើងដោយពួកវជ្ជីបុត្តកភិក្ខុសុំឲ្យកែ

ទាំងសិក្ខាបទចំនួន ១០ មាត្រាគឺ ១-សន្និធិការកសិក្ខាបទចែងថា : វត្ថុជាយាវកាលិក ភិក្ខុទទួលទុកឲ្យកន្លងរាត្រី ហើយយកមកឆាន់ត្រូវអាបត្តិបាចិត្តិយ, សុំតែថា : អំបិលដែលទុកក្នុងភាក់ស្នែង បើទុកជាកន្លងរាត្រី ក៏ភិក្ខុគួរឆាន់ជាមួយនឹងអាហារបិណ្ឌបាតដែលសាបបាន ។ល។ ១០-រូបិយសិក្ខាបទចែងថា : ភិក្ខុមិនត្រូវទទួលឬឲ្យគេទទួលមាសប្រាក់ ត្រេកអរចំពោះមាសប្រាក់ដែលគេទុកបម្រុងឲ្យខ្លួននោះទេ បើទទួលឬត្រេកអរត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ, សុំតែថា : បើមានដំណើរទៅណោះណោះត្រូវភិក្ខុទទួលកាន់និងប្រើប្រាស់បាន ។

រឿងនេះព្រះអរហន្តចំនួន ៧០០ រូប មានព្រះយសត្ថេរកាកណ្ឌបុត្រនិងព្រះរេវតត្ថេរព្រមទាំងព្រះសព្វកាមិត្ថេរជាដើម ឥតយល់ព្រមឲ្យតែទេ ។

ដូចនេះ លោកក៏ប្រជុំសង្ឃសន្និបាត សូត្រសាជាថ្មីឡើងវិញម្តងទៀត នូវធម្មវិន័យក្នុងកណ្តាលជំនុំសង្ឃចំនួន ១.២០០.០០០ រូប ជាលើកទី ២ ហៅថា ទុតិយសង្គាយនា ដើម្បីរម្ងាប់នូវអពុទហេតុនោះក្នុងវត្តវាលុការាម ក្រុងវេសាលី រដ្ឋវជ្ជី មានស្តេចកាឡាសោកជាអ្នកឧបត្ថម្ភ ទុតិយសង្គាយនានេះធ្វើ ៨ ខែ ទើបចប់ ។

តមកពួកវជ្ជីបុត្តកភិក្ខុបែកចេញទៅបង្កើតជានិកាយមួយ ហៅថា មហាសាំឃិកនិកាយ, ក្រោយមកក្នុង ព.ស. ២០០ ពួកមហាសាំឃិកនិកាយនេះបែកគ្នាជា ៥ និកាយគឺ : គោកុលិកា១ ឯកព្យោហារិកា១ បណ្ណត្តិវាទ១ ពហុលិយាវាទ១ ចេតិយវាទ១ (ជា៦ និងមហាសាំឃិកនិកាយ) ។ មានអាចារ្យវាទពីរបែកចេញពីថេរវាទគឺ : មហិសាសកា១ វជ្ជីបុត្តកា១ ។ ពួកអាចារ្យវាទនេះ ចេះតែបែកគ្នាតទៅទៀតគឺ : ធម្មុត្តរិយា១ ភទ្រយានិកា១

ឆន្នាគារិកា១ សម្មិតិយា១ សព្វត្ថិកា១ ធម្មគុត្តិកា១ កស្សបិកា១ សង្កន្តិកា១ សុត្តវាទ១ (ជា១២ និងគណៈជាថេរវាទ) រួមជា ១៨ និកាយ ។ ពួកនិកាយជាថេរវាទឥតបែកបាក់គ្នាទេ បែកគ្នាតែនិកាយជាមហាសាំឃិក និងជាអាចារិយវាទនោះ ។ ក្នុង ព.ស. ២០០ ឆ្នាំ នោះ ពួកមហាសាំឃិកនិកាយបែកទៅទិសខាងជើង គេហៅថា ឧត្តរនិកាយឬមហាយានិកនិកាយ ឯពួកនិកាយជាថេរវាទបែកមកទិសខាងត្បូង គេហៅថា ទក្ខិណនិកាយឬហីនយានិកនិកាយ (និកាយដែលកាន់តាមបែបសង្គាយនាទាំងពីរលើកនោះ ហៅថា ថេរវាទ) ។

កាលពុទ្ធសាសនាកំពុងផ្សាយទៅមាន់ពុទ្ធនាទាំង១៨ និកាយនោះ ។

កាលពុទ្ធសាសនាកំពុងផ្ញើវាសនាលើវាទៈទាំង ១៨ និកាយនោះ ។ ក្នុងរវាង ព.ស. ២១៤ ទៅ ២១៨ រហូតដល់ ព.ស. ២៣៤ ដែលពួកទក្ខិណនិកាយមកជុំគ្នានៅក្នុងក្រុងបាដលិបុត្រវត្តអសោការាមនោះ មានកើតអធិករណ៍យ៉ាងធំមួយទៀត ហើយសំណុំរឿងព្រមទាំងរឿងតតិយសង្គាយនានេះ នៅក្នុងរជ្ជកាលរបស់អសោកផង ។

មុននឹងនិយាយពីរឿងអធិករណ៍ និងរឿងតតិយសង្គាយនានោះ គួរនិយាយពីរឿងខត្តិយវង្សក្នុងជម្ពូទ្វីបក្រុងរាជគ្រឹះនោះជាដើមសិន ព្រោះរឿងនេះមានការទាក់ទងនឹងពុទ្ធសាសនាជិតស្និទ្ធណាស់ ។

## ៣-ខត្តិយវង្សក្នុងជម្ពូទ្វីបក្រោយពុទ្ធនិព្វាន

១-ព្រះបាទអជាតសត្តុ[១] សម្លាប់បិតាខ្លួនក្នុងឆ្នាំទី ៣៧ នៃពុទ្ធកាល

(១) អជាតសត្តុនេះ កាលនៅក្នុងផ្ទៃមាតានោះបណ្តាលឱ្យព្រះនាងវេទេហីជាមាតាចង់សោយលោហិតស្វាមី តែមិនហ៊ានប្រាប់ស្វាមីសោះ ទ្រាំទាល់តែស្គមរីងរៃ ទុកជាព្រះបាទពិម្ពិសារសួរក៏មិនប្រាប់ ។ ចុះព្រះនាងមិនប្រាប់ខ្ញុំជាប្តី តើព្រះនាងទុកប្រាប់អ្នកណាវិញ?. ថាខ្ញុំម្ចាស់ចង់ៗសោយលោហិតស្វាមី ហ៊ះសព្វបើបុំណ្ណឹងក៏ចាំលាក់ដែរ! នោះទ្រង់ឱ្យពេទ្យចាក់ព្រះហស្តស្តាំយកលោហិតឱ្យសោយ.ពួកហោរាទាយថា : កុមារនេះនឹងពិឃាតបិតាឯង ។

(ឆ្លង...)

ហើយសោយរាជ្យបាន ៨ ឆ្នាំ ទើបព្រះសម្ពុទ្ធបរិនិព្វាន, ក្រោយព្រះពុទ្ធបរិនិព្វាននោះ អជាតសត្តុសោយរាជ្យបាន២៤ឆ្នាំទៀត ទើបសុគត(ព.ស.២៤)។

២-ឧទយភទ្ទសម្លាប់អជាតសត្តុជាបិតាខ្លួនហើយ សោយរាជ្យបាន ១៦ ឆ្នាំ (រាជត្រកូលផ្លាស់ទៅនៅក្រុងបាដលិបុត្រ) (ព.ស. ៤០) ។

៣-អនុរុទ្ធជាបុត្រឧទយភទ្ទ និងមុណ្ឌៈជាបុត្រអនុរុទ្ធសម្លាប់បិតារៀងខ្លួន សោយរាជ្យបាន ៨ ឆ្នាំ (ព.ស. ៤៨) ។

៤-នាគទស្សកៈសម្លាប់មុណ្ឌៈជាបិតាហើយ សោយរាជ្យបាន ២៤ ឆ្នាំ ទើបពួកវង្សក្សត្រិយ៍ជនធ្វើរដ្ឋប្រហារសម្លាប់នាគទស្សកៈ និងវង្សស្តេចនេះទាំងអស់ (ព.ស. ៧២) ។

៥-កាលផុតពីពូជពង្សពួកស្តេចខាងលើនេះទៅ គេរើសយកសុសុនាគកុមារធ្វើស្តេច សុសុនាគ[២]នេះសោយរាជ្យបាន ១៨ ឆ្នាំ (ព.ស.៩០)។

៦-កាឡាសោកជាបុត្រសុសុនាគសោយរាជ្យបាន ២៨ ឆ្នាំ (ព.ស. ១១៨) ។

៧-រាជកុមារ ១០ រូប ជាបុត្រកាឡាសោកសោយរាជ្យបាន ២២ ឆ្នាំ (ព.ស. ១៤០) ។

---

ព្រះនាងវេទេហីឮព្រឹត្តិការណ៍នេះ ក៏លបចុះទៅក្នុងឧទ្យានរំលូតគភ៌ចោលតែមិនរលូត, លុះស្វាមីសង្កេតដឹងថា : ព្រះនាងធ្វើបែបនេះនាំឱ្យល្បីពេញជម្ពូទ្វីបហើយៗក៏ចាត់ឱ្យយាមរក្សា។ លុះប្រសូតមកគេយកទារកទៅលាក់ ទាល់តែធំបន្តិច ទើបយកមកបង្ហាញព្រះនាងៗលុះឃើញបុត្រ ក៏ស្រឡាញ់ឥតធ្វើអ្វីកើត, គេឱ្យនាមថា អជាតសត្តុ-សត្រូវនឹងបិតាខ្លួនតាំងពីមិនទាន់កើត។

(២) សុសុនាគនេះជាបុត្រស្រីពេស្យាក្រុងវេសាលី បិតាមិនប្រាកដ, កាលកើតមកជាដុំសាច់ មាតាឱ្យយកទៅចោលលើគំនរសម្រាម, ពស់នាគមកព័ទ្ធរក្សាក្លាយជាទារក, មនុស្សទៅមើលពស់នាគឱ្យសំឡេងឮសុសុហើយរត់បាត់, អាមាត្យបុត្រយកទារកនេះមកចិញ្ចឹមឱ្យឈ្មោះថា សុសុនាគ ។ ។

៨-ក្រោយពីពួកស្តេចទាំង ១០ រូបនោះមក មានពួកស្តេចនាមនន្ទា[៣] ចំនួន ៩ រូប សោយរាជ្យបាន ២២ ឆ្នាំដែរ (ព.ស. ១៦២) ។

៩-ចន្ទគុត្រ[៤] សោយរាជ្យបាន ២៤ ឆ្នាំ (ព.ស. ១៨៦) ស្តេចនេះកាន់សាសនាព្រាហ្មណ៍ ។

១០-ពិន្ទុសារ[៥] ជាបុត្រចន្ទគុត្រសោយរាជ្យបាន ២៨ ឆ្នាំ (ព.ស.២១៤) ស្តេចនេះកាន់សាសនាព្រាហ្មណ៍ដែរ ។ ព្រះបាទពិន្ទុសារនេះមានរាជបុត្រចំនួន ១០១ រូប មានអសោកកុមារជាដើម (មាតាអសោកជាវង្សសាក្យានីនាមនាងសិរីធម្មា) ។

១១-ចុងរជ្ជកាលនៃព្រះបាទពិន្ទុសារ គឺរវាង ព.ស. ២១៤ ទើប

---

(៣) ពួកស្តេចនន្ទានេះជាពួកសូទ្រ:, ថា : មានពួកចោរមួយក្រុមជំតែងដើរប្លន់អ្នកស្រុក ពេលមួយបានចាប់បុរសម្នាក់កំព្រាឪពុករកស៊ីចិញ្ចឹមម្តាយ ហើយយកបុរសនេះទៅប្លន់ជាមួយ លុះអ្នកស្រុកសម្លាប់មេចោរទៅ ពួកចោរឯទៀតលើកបុរសចិញ្ចឹមម្តាយនេះធ្វើជាមេចោរ បុរសក្លាហានគឺមេចោរថ្មីនេះថា: យើងត្រូវផ្លាស់ឈ្មោះខ្ញុំថាពួកនន្ទា១, ហើយឈប់រកស៊ីប្លន់អ្នកស្រុកត្រូវប្លន់យករាជសម្បត្តិវិញ ពួកនន្ទាប្រមូលពលបានច្រើនក៏ទៅប្លន់ដណ្តើមយករាជសម្បត្តិក្រុងបាដលិបុត្រ ដោយសម្លាប់ពួកបុត្រកាឡាសោកទាំងអស់ ហើយឡើងសោយរាជ្យហៅថា ពួកស្តេចនន្ទា ។

(៤) ចន្ទគុត្រនេះជាវង្សក្សត្រមោរិយ: ហើយជាពូជសាក្យ:ផង, ដំណាលថា កាលមោរិយក្សត្រចាញ់សង្គ្រាមនៃស្តេចសាមន្តរាជ, រាជទេវីនៃស្តេចមោរិយ:នេះមានគភ៌ចាស់ខែ ហើយភៀសខ្លួនទៅប្រសូតបុត្រនៀបទ្វារក្រោលគោ, នាយគោបាលឈ្មោះចន្ទបានយកកុមាររបស់ព្រះនាងនេះទៅចិញ្ចឹមឱ្យនាមថា ចន្ទគុត្រ, ពេលក្រោយ ចាណក្យព្រាហ្មណ៍បានសុំកុមារនេះពីចន្ទគោបាលយកទៅរៀនសិល្ប:, តមករាជកុមារចន្ទគុត្រនេះប្រមូលពលបានច្រើនទៅច្បាំងដណ្តើមរាជសម្បត្តិក្រុងបាដលិបុត្រដោយសម្លាប់ពួកស្តេចនន្ទាទាំងអស់ ។

(៥) កាលពិន្ទុសារនេះនៅក្នុងផ្ទៃមាតានៅឡើយ ចាណក្យព្រាហ្មណ៍ជាបុរោហិតបានផ្សំថ្នាំពិសដាក់ក្នុងនំថ្វាយស្តេចចន្ទគុត្រទុកការពារសត្រូវ, ស្តេចនេះហុចទៅឱ្យអគ្គមហេសីទុក ឯព្រះនាងមិនដឹងក៏យកនំនេះសោយ ចាណក្យព្រាហ្មណ៍ក្រឡេកឃើញទាន់ ក៏យកដាវកាត់កព្រះនាងការពារកុំឱ្យស្លាប់ទារក ភ្លាមនោះគេវះយកទារកទាំងស្រោមទៅបញ្ចូលក្នុងពោះមេពពែ ហើយដេរភ្ជិតភ្លាម, ៧ថ្ងៃទើបប្រសូត ហើយមានលោហិតស្រក់តក់ៗពីសិរីរៈទារក, ហេតុនោះ គេឱ្យនាមថា ពិន្ទុសារ ។

អសោកជាបុត្រធ្វើស្តេចមកទៀត ធ្វើស្តេចឥតគេអភិសេកចំនួន ៤ ឆ្នាំ, តែបានរាជាភិសេកពេញលក្ខណៈច្បាប់ក្នុង ព.ស. ២១៨ ឆ្នាំ ។

## ៤-ប្រវត្តិរបស់អសោក

អសោកកាលពីកម្លោះ ព្រះបាទពិម្ពិសារជាបិតាបញ្ជាឲ្យទៅនៅក្រុងឧជ្ជេនី វេន្តអវន្តិ, នាពាយ័ព្យទិសក្រុងបាដលិបុត្រ ធ្វើជាឧបរាជវេន្តនោះ ។

លុះធ្វើដំណើរទៅដល់ទីក្រុងតូចមួយហៅថា វេទិសនគរ នាកណ្ដាលផ្លូវនោះ ក៏ចូលទៅសម្រាកក្នុងផ្ទះសេដ្ឋីម្នាក់ឈ្មោះ វេទិសៈ បានឃើញសេដ្ឋីធីតានាមនាងវេទិសាមានរូបសម្បត្តិ និងលក្ខណៈសម្បត្តិដ៏ប្រិមប្រិយជាបុត្រីរបស់សេដ្ឋីនោះ ក៏បានដណ្ដឹងរៀបអាពាហ៍ពិពាហ៍ រួចនៅទីនោះ លុះនាងមានគភ៌ ទើបនាំហូសទៅនៅឯក្រុងឧជ្ជេនីឯណោះ ។

អសោក និងអគ្គជាយានេះ មានបុត្រមួយនាមមហិន្ទកុមារ ពីឆ្នាំកន្លងមកបានបុត្រីម្នាក់ទៀតនាមនាងសង្ឃមិត្តា ។

ពេលដែលកុមារ និងកុមារីមានអាយុកំពុងតែរត់លេងនោះ ក៏ស្រាប់តែអសោកបានទទួលព្រះរាជសារអំពីរាជទូតម្នាក់ថា : ព្រះបិតាមានអាពាធធ្ងន់ណាស់ !

ពត៌មានដ៏អាណោចអធម៌នេះ ធ្វើឲ្យអសោកញ័រយ៉ាងខ្លាំង ណាមួយអាណិតកូនប្រពន្ធ ណាមួយបិតាមានអាពាធ ប៉ុន្តែ ឱកាសគ្មានអនុញ្ញាតឲ្យអសោកបន្ថែបន្ថយបានឡើយ ដូច្នេះ អសោកត្រូវកាត់ចិត្តនាំប្រពន្ធកូនមកទុកឯក្រុងវេទិសានគរជាស្រុកកំណើតភរិយា, ទុកជាប្រពន្ធកូនអង្វរករសុំទៅជាមួយយ៉ាងណាក៏មិនបាន ព្រោះមាគ៌ាឆ្ងាយណាស់ហើយការនេះជាបន្ទាន់ផង។

ពេលដែលប្រពន្ធកូនកំពុងឈរយំតាមមើលដំណើរប្ដី និងឪពុក,

នោះអសោកបំផ្លាយអស្សតរយ៉ាងលឿន ដោយងាកមើលប្រពន្ធកូនសម្រក់ជលនេត្រលើខ្នងអស្សតរម្តងៗ ។

លុះទៅដល់ក្រុងបាដលិបុត្រ បិតាក៏សុគតផុតក្ខាម, អវសាននៃឈាបនកិច្ចសពនេះរួច អសោកក៏ចាត់ការយករាជសម្បត្តិ តែអនុជទាំងអស់ដែលមានមាតាផ្សេងពីអសោកមិនយល់ព្រមឲ្យរាជសម្បត្តិទៅអសោកឡើយ រឿងនេះកើតជាចម្បាំងយ៉ាងធំ តែទីបំផុតជ័យជំនះបានមកអសោក ដោយអសោកសម្លាប់ប្អូនៗចោលទាំងអស់ ទុកតែតិស្សកុមារម្នាក់ដែលរួមមាតាជាមួយនឹងខ្លួន ។

ក្នុងព្រឹត្តិការណ៍ដ៏អាស្រូវនេះ អសោកធ្វើស្តេចឥតគេអភិសេកចំនួន ៤ ឆ្នាំ លុះក្នុង ព.ស. ២១៨ ទើបគេធ្វើរាជាភិសេកអសោកពេញច្បាប់ជាមួយនឹងព្រះនាងអសន្ធិមិត្តាដែលជាស្ត្រីមានបុញ្ញាភិនិហារ និងលក្ខណៈសម្បត្តិឯកមួយ ឲ្យសោយរាជ្យក្នុងក្រុងបាដលិបុត្រ អសោកមានអំណាចឥតគណនា បានផ្សាយអាណាចក្ររបស់ខ្លួនពេញជម្ពូទ្វីបទាំងមូល ។

ឫទ្ធានុភាពរបស់អសោកនេះ មិនត្រឹមតែផ្សាយព្រោចទៅលើមនុស្សក្នុងជម្ពូទ្វីបប៉ុណ្ណោះទេ តែគង់ផ្សាយព្រោចទៅលើអាកាសុទកាល័យ និងក្រោមដីចំនួន ១ យោជន៍ផងដែរ, ហេតុនោះបានជាគេឃើញពួកទេវតានាំជន្ទាយមកថ្វាយរាល់ទិវារាត្រី ដូចជាទឹកអនោតត្តស្រះ, ឈើស្ទន់, ថ្នាំកែរោគ ផ្លែស្វាយទុំ, សំពត់ស្លៀកពាក់,កន្សែងសម្រាប់ជូតដៃ និងទឹកអប់ទិព្វជាដើម។ ឯពួកស្តេចនាគក៏នាំជន្ទាយមកថ្វាយរាល់ទិវាកាលដែរ ដូចជាគ្រឿងក្រអូបសម្រាប់កក់ក្បាល, សម្រាប់លាប, សំពត់ទិព្វមិនមែនអម្បោះ, កម្រងផ្កាម្លិះ និងថ្នាំបន្តក់ភ្នែកជាដើម ។

ឯសត្វសេកទាំងហ្វូងៗ ក៏នាំស្រូវសាលីទាំងទេះៗពីឆទ្ទន្តស្រះមក ទំលាក់ថ្វាយកល់ថ្ងៃដែរ ។

ឯសត្វកណ្តុរជាអ្នកធ្វើអង្ករមិនឲ្យមានកន្ទក់ថ្វាយកល់ថ្ងៃដែរ។ សត្វឃ្មុំក៏មកធ្វើសម្បុកក្បែរៗព្រះរាជនិវេសន៍ និងទីនានា, ឯសត្វខ្លាឃ្មុំជាអ្នកឡើងដើមឈើយកឃ្មុំនោះមកថ្វាយអសោក ។

ឯសត្វករវិកបបួលគ្នាហើរព្រោចពាសពេញរាជនិវេសន៍ ប្រគំស្នាប និងសម្លេងពិរោះរបស់គេ ថ្វាយអសោកកល់ទិវារាត្រី ។

វត្ថុដែលគេនាំថ្វាយទាំងប៉ុន្មាន អសោកតែងប្រគេនដល់ព្រះសង្ឃ ចំនួន ៨ ភាគ ១០ និងប្រគេន ២ ភាគ ១០ ដល់ព្រះសង្ឃដែលចេះចាំទូវបិដកទាំង៣ ចំនួន ៦០ អង្គ, ពេលណាដែលលោកជ្រះថ្លាក្នុងពុទ្ធសាសនាហើយនោះ ។

ក្រៅពីនោះ ទ្រង់ប្រទានដល់អគ្គមហេសីនាមអសន្ធិមិត្តាចំនួន២ភាគ ហើយសម្រាប់ស្រីពៅ និងខ្លួនលោកពីរភាគដែរ ។

តែអសោកដូចជាភ្លេចអត្តជាយាកំសត់ និងបុត្រពីររូបនៅក្រុងវេទិ-ស: ដែលគ្នាកំពុងយំសោករងចាំមើលផ្លូវ និងទន្ទឹងចាំកសនារបស់ខ្លួននោះ។

ឱនារី និងបុត្រកំព្រា ! ពេលអសោកចេញចោលផុតមក នាង និង បុត្រពីររូប តែងទន្ទឹះខ្សឹកខ្សួលនឹកស្វាមីជានិច្ច ថ្ងៃមួយលុះចាំស្វាមីបាត់ដំណឹងយូរពេក ក៏ដាច់ចិត្តនាំបុត្រទាំងពីរមកអង្គុយសញ្ជប់សញ្ជឹងចាំស្ដាប់តែពត៌មាន ។

ជា : ពេលដែលគេរៀបរាជាភិសេកអសោកពេញច្បាប់នោះ ម-ហិន្ទកុមារមានអាយុ ១៤ ឆ្នាំហើយ ឯនាងសង្ឃមិត្តាមានអាយុ ១២ ឆ្នាំ

ហើយដែរ, តែមាតារបស់កុមារ កុមារិកានេះមិនព្រមនាំបុត្រទៅជួបអសោកឡើយ ប្រហែលជានាងដឹងថា អសោកមានអគ្គមហេសីថ្មីទៀតនោះហើយមើល៍ ?

ប៉ុន្តែពេលរាជាភិសេកអសោកពេញច្បាប់នោះ បុត្រទាំងពីរនេះដោយចង់ឃើញមុខបិតាគេ ក៏យំអុកឡុកម្ដាយពន់ពេក មាតាក៏ឲ្យគេនាំបុត្រទាំងពីរនេះទៅ ហើយផ្ដាំថា : បើមានការសុខ-ទុក្ខអ្វីចាប់ពៃមកវិញ និងចាប់ឲ្យពត៌មានមកម្ដាយវិញណាកូន !

បុត្រទាំងពីរនេះបានជួបបិតាគេដោយសុវត្ថិភាព អសោកស្រឡាញ់បុត្រទាំងពីរនេះដូចជាបណ្ដូលចិត្ត ទាំងព្រះនាងអសន្ធិមិត្តាក៏ស្រឡាញ់បុត្រទាំងពីរនេះដូចបុត្របង្កើតរបស់ព្រះនាង ។

## ៥-បុញ្ញានុភាពរបស់ព្រះនាងអសន្ធិមិត្តា

ព្រះនាងអសន្ធិមិត្តានេះ មានរូបសម្បត្តិល្អមិនមានស្នាមតំណគឺល្អមិនទាស់ភ្នែក ហើយជាពុទ្ធមាមកាមានសទ្ធាបំផុតក្នុងពុទ្ធសាសនា, ថ្ងៃមួយអសោក និងព្រះនាងបាននិមន្តព្រះសង្ឃចំនួន ៦០.០០០ អង្គឆាន់ លុះលោកឆាន់រួចហើយ អសោក និងព្រះនាងក៏យាងទៅដំណាក់រៀងខ្លួន ។

ដើមរាត្រីនោះ អសោកបានចូលទៅបន្ទប់ព្រះនាងដែលកំពុងសោយទឹកអំពៅ អសោកបានចំអន់លេងថា : ព្រះនាងមានក័ក្រល្អណាស់គង់លើកាពូនៈកៅអីសោយទឹកអំពៅធ្វើនេត្រាតូចធំៗ ប្រហែលជាឆ្ងាញ់ណាស់ហើយមើល៍ ?

ដោយមានអ្នកគាបអំពៅនៅក្បែរនោះផង ព្រះនាងអសន្ធិមិត្តាក៏ទឹកអៀនតូចព្រះទ័យនឹងពាក្យចំអន់នោះ, ទើបព្រះនាងទូលតមាត់ថា : ខ្ញុំម្ចាស់

សោយតែទឹកអំពៅដែលទេវតានាំមកថ្វាយខ្ញុំទេតើ ? ដោយអំពៅនោះកើតដោយសារបុណ្យខ្ញុំម្ចាស់ !

អសោកខ្ញាល់ក៏ចាប់ទោសថា : ឥស្សរិយយសទាំងអស់ក្តី សម្បត្តិទ្រព្យទាំងអស់នេះក្តី វាសុទ្ធតែកើតដោយសារបុណ្យនាងទាំងអស់ហើយ នាងនិយាយនេះបង្អាប់កិត្តិយសខ្ញុំហួសពេក ទុកខ្ញុំដូចមនុស្សនរកទៅហើយ, តែណ្ហើយចុះ ស្អែកនេះយើងនិមន្តព្រះសង្ឃ ៦០.០០០ អង្គមកឆាន់ទៀត ហើយនាងរកត្រៃចីវរ ៦០.០០០ ត្រៃមកប្រគេនលោកឲ្យបាន ឲ្យខ្ញុំបានដឹងបុណ្យរបស់នាងផង ។

បើនាងរកមិនបានទេ នោះនាងត្រូវទទួលទណ្ឌកម្មជាទម្ងន់បំផុត អសោកថាតែប៉ុណ្ណោះក៏ថយចេញទៅបាត់ ។

ក្រោយនោះព្រះនាងអសន្ធិមិត្តាទ្រង់កន្ទ្រើងសោយសោកឱនទឹកមុខស្រពោនដូចផ្កា នាងដកដង្ហើមធំហើយអ៊ូរទាំតែក្នុងទ្រូងថា : ឱស្វាមីអើយ! មិនគួរខ្ញាល់ចាប់កំហុសខ្ញុំសោះ ! ឲ្យខ្ញុំទៅរកត្រៃចីវរឯណាទាំងរាត្រីនេះបាន? ព្រះនាងព្រួយណាស់ដើរចុះ-ឡើង ផ្ទំក៏មិនលក់ ហើយស្ទុះក្រោកទៅយំសម្រក់ទឹកនេត្រលើមុខបុត្រនាងបន្តិច វិលមកអង្គុយបន្តិច រសាប់រសល់ឥតលក់សោះនារាត្រីនោះ ។

ពេលនោះស្តេចទេវតាទាំង ៤ បញ្ជាឲ្យស្តេចកុវេរវេស្សវណ្ណយកប្រអប់សំឡីទិព្វមកថ្វាយព្រះនាង, ស្តេចនេះលុះទៅដល់នាងហើយក៏ថា : ព្រះនាងកុំសោកបារម្ភអ្វី ប្រអប់នេះជារបស់ទិព្វ នាងប្រាថ្នាអ្វីបានទាំងអស់ រួចក៏លានាងបាត់ទៅ ។

លុះព្រឹកឡើង ព្រះសង្ឃចំនួន ៦០.០០០ អង្គមកឆាន់ លោកឆាន់

រូប អសោកថា : ចូរព្រះនាងយកត្រៃចីវរមកប្រគេនលោក ! ព្រះនាងក៏ថ្វាយប្រអប់ទិព្វនោះភ្លាម ស្រាប់តែត្រៃចីវរចេញពីប្រអប់នោះមកទាំងត្រៃៗ បានគ្រប់ព្រះសង្ឃទាំងអស់, អសោកបែបស្រឡាំងកាំងមិនចេញស្តីអ្វីសោះរួចហើយក៏ក្រោកទៅជំណាក់រៀងខ្លួន ។

បន្ទាប់នោះ អសោកបញ្ជាឲ្យគេយាងព្រះនាងអសន្ធិមិត្តាមកក្នុងកណ្តាលចំណោមមុខមន្ត្រី អសោកនិយាយលន់តួថា : សូមព្រះនាងអត់ទោសដល់ខ្ញុំផង ហើយដោះសារថា ខ្ញុំចង់ដឹងបុណ្យនាងទេតើ !

ព្រះនាង..., ខ្ញុំម្ចាស់ឥតយកទោសស្វាមីទេ ស្វាមីទេតើយកកំហុសខ្ញុំម្ចាស់ !

អសោក..., ខ្ញុំដឹងបុណ្យព្រះនាងហើយ ពីពេលនេះទៅមុខឥស្សរិយការពទាំងអស់ព្រមទាំងស្រ្តីបាំចំនួន ១៦.០០០ រូប ក្នុងបុរីនេះ ខ្ញុំសូមប្រគល់ថ្វាយនាងជាដាច់ខាត ។

ពួកស្រ្តីទាំងនោះបបួលគ្នានិន្ទាអសោក, អសោកចាត់ឲ្យនាយពិសេសចំអិននំចំនួន ១៦.០០០ ហើយបន្តប់ព្រះទម្រង់មួយវង់កាត់ថ្លៃមិនបានក្នុងនំមួយ ឲ្យស្រ្តីរបាំទាំង ១៦.០០០ រូប ទាំងព្រះនាងអសន្ធិមិត្តាផង រើសយកនំមួយម្នាក់ៗ ឯព្រះនាងអសន្ធិមិត្តាបានរើសយកនំក្រោយគេបំផុត រួចហើយទ្រង់ឲ្យបកនំនោះមើល នំដែលបន្តប់ព្រះទម្រង់នោះបានលើព្រះនាងអសន្ធិមិត្តា, អសោកថា : នាងរាល់គ្នាឃើញឬទេ គឺ នាងរាល់គ្នាជាស្រ្តីឥតបុណ្យ ឯព្រះនាងអសន្ធិមិត្តាទើបជាស្រ្តីមានបុណ្យឯក ដូច្នេះនាងរាល់គ្នាឈប់ច្រណែនឫស្សាទៅ ។ ព្រះនាងអសន្ធិមិត្តាទាញសំពត់ពីប្រអប់ទិព្វ ១.០០០ ក៏ថ្វាយស្វាមី និងទ្រង់ប្រទានដល់ឧបរាជ-មុខមន្ត្រី និងយុវនារី

នោះៗ ចំនួន ៥០០ កហាបណ៍ម្នាក់ៗផងដែរ, ហើយប្រទានដល់ពលហៅ និងជន សាមញ្ញចំនួន ៥០ កហាបណ៍ម្នាក់ៗ ។

អសោករន្ធត់ចិត្តព្រឺខ្លួនខ្លាចៗ ក៏សួរថា : ព្រះនាងបានវត្ថុពិសេស ទិព្វនេះពីណាមក !

បពិត្រស្វាមី ! ប្រអប់ទិព្វនេះស្តេចទេវតានាមកុវេរៈឲ្យខ្ញុំ កើត ដោយសារបុណ្យដែលខ្ញុំម្ចាស់បានប្រគេនក្រមាមួយជាចីវរដល់ព្រះបច្ចេកពុទ្ធ ក្នុងអតីតកាល ។

បពិត្រស្វាមី ! បើខ្ញុំម្ចាស់ចង់ឲ្យនូវសំពត់ឬឲ្យវត្ថុអ្វីមួយឬក៏ខ្ញុំចង់ ប្រាថ្នានូវអ្វីៗ ក៏បានសម្រេចដោយប្រអប់បុណ្យនេះដែរ ។

បពិត្រស្វាមី ! សូមស្វាមីរិតរំឲ្យទាន, សូមស្វាមីធ្វើបុណ្យកុសល ឲ្យញយៗ, សូមស្វាមីរក្សាសីលកុំឲ្យដាច់, សូមស្វាមីទូន្មានចិត្តឲ្យល្អកុំក្រេវ ក្រោធឥតសមហេតុ-ផល, សូមស្វាមីសេពគប់តែកល្យាណមិត្រ, សូម ស្វាមីកុំបណ្តែតបណ្តោយឲ្យលង់ស្មារតី, ស្វាមីប្រព្រឹត្តធម៌, សូមស្វាមីរក្សា រាស្ត្រតាមសមធម៌, សូមស្វាមីកុំប្រើអំណាចទៅលើមនុស្សដែលទន់ខ្សោយ ជាងខ្លួន ធ្វើបែបនេះទើបស្វាមីបានលទ្ធផលល្អ (សំដីដ៏ពីរោះមានន័យនេះមុត ជាប់ក្នុងបេះដូងអសោកចាំមិនភ្លេចរហូតសុគត) ។

## ៦-សេចក្តីជ្រះថ្លារបស់អសោក

ថា : អសោកធ្លាប់បានឃើញរូបពុទ្ធនិម្មិតដែលកាឡនាគរាជនិម្មិត ថ្វាយកើតបីតិសោមនស្ស ទើបទ្រង់ឈរបូជាមិនប្រិចព្រះនេត្រ មិនសោយ អាហារចំនួន ៧ ថ្ងៃ ចាប់ពីបានទតឃើញពុទ្ធនិម្មិតនោះ ។

ថា : អសោករាជាភិសេកបាន ៣ ឆ្នាំ នោះទៅប្រកាន់តាមលទ្ធិ-

ព្រាហ្មណ៍ដែលជាគតិបិតាលោកនៅឡើយ, លុះរាជាភិសេកបាន ៤ ឆ្នាំ ទើបជ្រះថ្លាស៊ប់ក្នុងពុទ្ធសាសនា គឺដោយសារតែទ្រង់បានឃើញ និងបានស្ដាប់នូវធម្មទេសនារបស់ព្រះអរហន្តមួយរូបនាម និគ្រោធ[៦]សាមណេរជាក្មួយនោះឯង ។

ថា : អសោកមានសទ្ធាមិនញាប់ញ័រ ទ្រង់បិតក្នុងសីល ៥ ជានិច្ច, ហើយឧបត្ថម្ភព្រះសង្ឃ និងឲ្យកសាងវត្តចំនួន ៨៤.០០០ មានអសោការាមជាដើមសម្រាប់ព្រះសង្ឃនៅ និងឲ្យកសាងព្រះចេតិយចំនួន ៨៤.០០០ គ្រប់នគរទាំង ៨៤.០០០ នគរក្នុងជម្ពូទ្វីបដែលជាអាណាចក្ររបស់ខ្លួន ។

ចំនួននេះទុកជាសក្ការបូជាចំពោះព្រះធម៌របស់ព្រះពុទ្ធចំនួន ៨៤.០០០ ធម្មក្ខន្ធនោះ ។ ការកសាងនេះចំនួន ៣ ឆ្នាំ ទើបហើយ ។ (ថា : អសោកបានឲ្យប្រមូលព្រះសារីរិកធាតុទាំងអស់របស់ព្រះសម្ពុទ្ធក្នុងជម្ពូទ្វីបមកបញ្ចុះក្នុងព្រះចេតិយថ្មីនេះ ហើយឲ្យសាងសិលាចារឹកគ្រប់សំរេជនីយដ្ឋាន និងពោធគយាផង) ។

ថា : ក្នុងថ្ងៃធ្វើបុណ្យឆ្លងសមិទ្ធិចំនួន ៧ ថ្ងៃ យប់នោះអសោកព្រមទាំងពលរេហ៍ទាំងអស់បានយាងអញ្ជើញទៅវត្ត ហើយគង់កណ្ដាលព្រះភិក្ខុសង្ឃ សុទ្ធតែសមាទានសីល ៨ ទាំងអស់គ្នា ។

---

(៦) កាលអសោកសម្លាប់បិតារបស់សាមណេរនេះៗនៅក្នុងឧទរមាតានៅឡើយ សុមនាទេវីជាមាតាសាមណេរនេះភ័យខ្លាចអសោកសម្លាប់នាងទៀត ក៏គេចខ្លួនដើរកាត់ព្រៃ ហើយក៏ប្រសូតបុត្រក្រោមដើមជ្រៃលើវេទិកាល្អមួយដែលទេវតានិម្មិតថ្វាយ. អ្នកស្រុកចណ្ឌាលជួយទំនុកបម្រុងនាង និងទារកនេះៗនាងឱ្យនាមថា និគ្រោធកុមារ លុះកុមារនេះមានអាយុ ៧ ឆ្នាំ មហាវរុណត្ថេរសុំយកទៅបំបួសជាសាមណេរបានសម្រេចព្រះអរហត្តថ្ងៃមួយលោកនេននេះនិមន្តកាត់មុខវាំងទៅប្រោសញោមស្រីលោក អសោកឃើញក៏ស្រឡាញ់-ជ្រះថ្លាចំពោះឥរិយាបថលោកនេននេះ ទើបនិមន្តចូលវាំងឱ្យសម្ដែងធម៌ ។

ថា : ក្នុងមហាសន្និបាតនោះមានភិក្ខុសង្ឃចំនួន ៨០ កោដិ ភិក្ខុនី-សង្ឃចំនួន ៩៦ សែនរូប ក្នុងចំនួននោះមានភិក្ខុ-ភិក្ខុនីជាព្រះអរហន្តចំនួន ១០០.០០០ អង្គ ។

ដោយចង់ឲ្យអសោកជ្រះថ្លាជាភិយ្យោភាពទៀតនោះ ព្រះអរហន្តទាំងឡាយបានសំដែងបាដិហារ្យឲ្យអសោកទតជម្ពូទ្វីប, ឃើញទាំងអស់ទល់ទីងមាត់សមុទ្រ ។ ថា : ពេលធ្វើបុណ្យសម្ពោធនេះ មនុស្សទៅតាមើលធ្លាឃើញទាំងអស់។ (ថា : អសោកដោយជ្រះថ្លាខ្លាំងបានបួសចំនួនពីរវស្សា)។

ថា : អសោកសួរព្រះភិក្ខុសង្ឃថា ក្នុងពុទ្ធសាសនានេះ មានជនណាបរិច្ចាគធំជាងបុណ្យនេះឬទេ ?

ព្រះមោគ្គលីបុត្តតិស្សត្ថេរថា : សូមជ្រាបទុកជាកាលព្រះពុទ្ធគង់នៅ ក៏មិនមានជនណាបរិច្ចាគធំយ៉ាងនេះឡើយ ។

អសោករឹតតែរីករាយជ្រះថ្លាជាអនេកប្បការទៀត, ដូច្នេះ ខ្ញុំព្រះករុណាបាននាមថាជាសាសនទាយាទគឺជាសាច់ញាតិ និងពុទ្ធសាសនាហើយឬ?

ព្រះមោគ្គលីបុត្ត.....លុះតែទ្រង់ឲ្យបុត្រធីតាបួសទៀត ទើបបានព្រះនាមថា ជាសាសនទាយាទក្នុងពុទ្ធសាសនា ។

ពេលនោះមហិន្ទកុមារមានអាយុ ២០ ឆ្នាំគត់ ឯនាងសង្ឃមិត្តាមានអាយុ ១៨ ឆ្នាំ ហើយនាងមានបុត្រមួយឈ្មោះសុមនកុមារទៀតផង, តែតាំងពីស្វាមីនាងឈ្មោះអគ្គិព្រហ្ម (ក្មួយអសោក) បួសជាមួយនឹងតិស្សឧបរាជដែលជាប្អូនរបស់អសោកនោះទៅ, ព្រះនាងក៏នៅមេម៉ាយ ឯនាទីឧបរាជក៏នៅទំនេរ ដូច្នេះ នាទីឧបរាជនេះអសោកប្រុងឲ្យទៅមហិន្ទកុមារជាបុត្រ ។

ប៉ុន្តែ លុះទ្រង់ឮថេរដីកាដូច្នោះ ក៏ទ្រង់បែរមកពិភាក្សានឹងបុត្រទាំង

ពីនោះ ឯបុត្រធីតាទាំងពីរក៏ព្រមបួសដោយសេចក្តីសោមនស្ស ។

គ្រានោះ គេឃើញព្រះមោគ្គលីបុត្តតិស្សត្ថេរជាឧបជ្ឈាយ៍ ព្រះមហាទេវត្ថេរជាកម្មវាចា ព្រះមជ្ឈន្តិកត្ថេរជាអនុស្សាវនៃ បំបួសមហិន្ទកុមារនោះ ។ បួសហើយមិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទា ។

ឯនាងសង្ឃមិត្តា គេឃើញអាយុបាលិត្ថេរីជាអាចារ្យធម្មបាលិត្ថេរីជាឧបជ្ឈាយ៍បំបួសជាសាមណេរី ហើយឲ្យសិក្សានូវសិក្ខាបទ ៦ មានបាណាតិបាតវេរមណីជាអាទិ អស់រយៈកាលពីរឆ្នាំ ទើបបំបួសជាភិក្ខុនី តមកក៏បានសម្រេចព្រះអរហន្តដែរ ។

ថា : កាលបុត្រទាំងពីរនេះបួស អសោករាជាភិសេកបាន ៦ ឆ្នាំហើយ (ព.ស. ២២៤) មហិន្ទត្ថេរបួសបាន ៣ ឆ្នាំ ទើបរៀនចប់នូវបិដកពិនិងអដ្ឋកថាព្រមទាំងថេរវាទ ហើយបានជាប្រធាននៃសិស្សចំនួន១.០០០ រូប នោះអសោករាជាភិសេកបាន ៩ ឆ្នាំ (ព.ស. ២២៧) ។

តពីនោះមក អសោកតែងចំណាយព្រះរាជទ្រព្យចំនួន ៥០០.០០០ កហាបណៈរាល់ៗថ្ងៃគឺ ១០០.០០០ សម្រាប់និគ្រោធត្ថេរជាក្មួយ,១០០.០០០ សម្រាប់ពុទ្ធបូជា, ១០០.០០០ សម្រាប់ធម្មបូជា,១០០.០០០ សម្រាប់សង្ឃបូជា, ១០០.០០០ សម្រាប់មន្ទីរពេទ្យ និងថ្នាំឱសថចែកក្នុងជ្រុងទ្វារនគរទាំង ៤ ទិស ។ (ថា : អសោកមានតែផ្លែស្រមោ និងកន្ទួតព្រៃមួយក៏ផ្ញើទៅវត្តប្រគេនសង្ឃដែរ) ។

ពេលនោះលាភសក្ការៈកើតចំពោះពុទ្ធសាសនាច្រើនជាអនេកអនន្ត, នាំឲ្យពួកនិគ្រណ្ឋតិរ្ថិយចូលមកបន់បួសបួមដើម្បីលាភនោះ, ថែមទាំង

ពោលបំភ្លាត់ធម្មវិន័យ បន្តចលនាអធិករណ៍ពាសពេញក្នុងវត្តអារាមឥតអ្នកណារម្ងាប់បាន, ឯភិក្ខុសង្ឃបរិសុទ្ធក៏ឈប់ធ្វើសង្ឃកម្មទាំងអស់ជាមួយនឹងពួកនោះ ។

ព្រះមោគ្គលីបុត្តតិស្សត្ថេរ កាលមិនអាចរម្ងាប់អធិករណ៍នេះបាន លោកក៏ប្រគល់ការសង្ឃឲ្យមហិន្ទត្ថេរគ្រប់គ្រង ខ្លួនលោកក៏កៀសទៅនៅឯភ្នំអហោគង្គាឯណោះ ។

ក្នុងអសោការាមទាំងមូល លែងមានឧបោសថអស់រយៈកាលចំនួន ៧ ឆ្នាំ (អសោកកជាភិសេកបាន ១៦ ឆ្នាំ មហិន្ទត្ថេរបួសបាន ១០ វស្សាហើយ (ព.ស. ២៣៤) ។

គ្រានោះអសោកធម្មរាជបញ្ជាឲ្យសេនាមាត្យទៅជួយរម្ងាប់អធិករណ៍នេះ តែអាមាត្យល្ងង់នោះបែរជាសម្លាប់ពួកភិក្ខុអស់ជាច្រើន ។

រឿងឃាតកម្មនេះនាំឲ្យអសោកភ័យរន្ធត់យ៉ាងខ្លាំង ទើបទ្រង់ចាត់សមណទូត និងសេនាមាត្យជាច្រើនលើកឲ្យទៅនិមន្តព្រះមោគ្គលីបុត្តតិស្សត្ថេរមកវិញ ។

លុះព្រះមោគ្គលីបុត្តតិស្សត្ថេរមកដល់ បានពន្យល់នូវហេតុការណ៍ផ្សេងៗនៃលទ្ធិពុទ្ធសាសនាចំនួន ៧ ថ្ងៃថ្វាយឲ្យអសោកយល់, ថ្ងៃទី៧នោះ អសោកបញ្ជាឲ្យបិទបាំងរនាំងជាសង្កាត់ៗ ហើយឲ្យសង្ឃទាំងអស់ក្នុងអសោការាម អង្គុយជុំគ្នាដោយពួកៗតាមលទ្ធិរឿងៗខ្លួនក្នុងសង្កាត់នោះៗ រួចទើបទ្រង់សួរមួយពួកម្តងៗ ថា :

ព្រះសម្ពុទ្ធទ្រង់ពោលអាងអ្វី ?

ក្រុមទីមួយៗសុទ្ធតែពោលតាមលទ្ធិ និងទិដ្ឋិខុសពីពុទ្ធសាសនា, នោះទ្រង់ឲ្យផ្សឹកចេញទាំងអស់ចំនួន ៦០.០០០ រូប, ទុកតែក្រុមណាដែលឆ្លើយថា : ព្រះសម្ពុទ្ធទ្រង់ពោលអានកម្មផល ។

រួចហើយព្រះសង្ឃទាំងឡាយ ក៏បបួលគ្នាធ្វើសាមគ្គីឧបោសថក្នុងអាវាសនោះ ។

## ៧-តតិយសង្គាយនា

កាលព្រះមោគ្គលីបុត្តតិស្សត្ថេរបានម្ចាប់ទូវបម្សៀងគីលទ្ធិពួកតិត្ថិយរួចហើយ ដោយមានលោកជាប្រធាន ក៏បានរើសព្រះអរហន្តបដិសម្ភិទា និងវិជ្ជា៣ ចំនួន ១.០០០ រូប មានមហិន្ទត្ថេរជាដើម ពីក្នុងចំណោមភិក្ខុ ៦០ សែនអង្គនោះមកប្រជុំគ្នាក្នុងវត្តអសោការាមជិតក្រុងបាដលិបុត្រ ធ្វើតតិយសង្គាយនាដូចសង្គាយនាទី១ និងទី២ដែរ ជាពិសេសលោកបានសម្តែងកថាវត្ថុដោយពិស្តារ ឯអសោកជាអ្នកឧបត្ថម្ភ, តតិយសង្គាយនានេះចាប់ធ្វើក្នុង (ខែទី៨ខាងមុខអំពី) ព.ស. ២៣៤ ឆ្នាំ, ៩ ខែទើបចប់ ។

រួចហើយដោយលោកយល់ថា : ពុទ្ធសាសនានឹងទៅប្រតិស្ឋានក្នុងបច្ចន្តជនបទនោះ ទើបព្រះមោគ្គលីបុត្តតិស្សត្ថេរបានចាត់ព្រះអរហន្តជាសមណទូតចំនួន ៩ ក្រុម ក្នុងក្រុមទីមួយៗមានភិក្ខុ ៥ រូប ឲ្យទៅប្រកាសផ្សាយព្រះពុទ្ធសាសនាក្នុងបច្ចន្តជនបទដូចតទៅនេះគឺ :

-ក្រុមទី១ មានមជ្ឈន្តិកត្ថេរជាប្រធាន ទៅរដ្ឋកស្មីរ និងរដ្ឋគន្ធារ ។

-ក្រុមទី២ មានមហាទេវត្ថេរជាប្រធាន ទៅរដ្ឋមហិសកមណ្ឌល ។

-ក្រុមទី៣ មានរក្ខិតត្ថេរជាប្រធាន ទៅរដ្ឋវនវាសី ។

-ក្រុមទី៤ មានយោនកធម្មរក្ខិតត្ថេរជាប្រធាន ទៅរដ្ឋអបរន្តកៈ ។

-ក្រុមទី៥ មានមហាធម្មរក្ខិតត្ថេរជាប្រធាន ទៅមហារដ្ឋ ។

-ក្រុមទី៦ មានមហារក្ខិតត្ថេរជាប្រធាន ទៅរដ្ឋយោនកៈ ។

-ក្រុមទី៧ មានមជ្ឈិមត្ថេរជាប្រធាន ទៅតំបន់ហិមវន្តប្រទេស ។

-ក្រុមទី៨ មានសោណកត្ថេរ និងឧត្តរត្ថេរជាប្រធាន ទៅសុវណ្ណ-ភូមិ(៧) ។

-ក្រុមទី៩ មានព្រះមហិន្ទត្ថេរជាប្រធាន មានអរហន្ត ៤ រូបជាសមាជិកគឺ ឥដ្ឋិយត្ថេរ១ ឧត្តិយត្ថេរ១ សម្ពលត្ថេរ១ ភទ្ទសាលត្ថេរ១ ទៅតម្ពបណ្ណិទ្វីប ឬ លង្កាទ្វីប ។

ថា : ព្រះមហិន្ទត្ថេរនេះ មុននឹងទៅលង្កាទ្វីបជាមួយនឹងអរហន្ត៤រូបនោះ លោកក៏យកព្រះអរហន្តមួយរូបទៀតនាមសុមនសាមណេរជាបុត្រនាងសង្ឃមិត្តាថេរី ដែលត្រូវជាក្មួយលោកនោះទៅជាមួយដែរ ។

តែដោយឱកាសមិនទាន់អនុញ្ញាតឲ្យលោកទៅភ្លាមៗនោះ លោកក៏ថ្វាយបង្គំលាគ្រូ និងព្រះសង្ឃ នាំអរហន្ត ៥ រូបនេះ ទៅសំចតនៅឯវេទិស-នគរជាស្រុកញាតិញោមស្រីរបស់លោក ឯញោមស្រីនោះគ្រាន់តែក្រឡេកឃើញមុខកូនមកដល់ ក៏ស្ទុះទៅឱបជើងយំ រួចសួរអំពីកូនស្រី និងចៅផងដែរ, ឯសុមនសាមណេរក៏បង្ហាញខ្លួនភ្លាម សេដ្ឋីធីតានេះក៏ស្ទុះទៅស្ទើរតែគ្រកនឹងបីចៅនោះទៀត ។

រួចនាងរៀបចាត់ចែងចង្ហាន់ដោយដៃនាងប្រគេនក្នុងទីអាវាសាន ព្រះ

(៧) ភូមិភាគនៃដីសណ្តមួយជ្រោយមានជាតិមាសច្រើន ហើយមានប្រវែងចំនួន ៧០០ យោជន៍ពីមជ្ឈិមប្រទេសនេះហៅថា សុវណ្ណភូមិ. បើទៅតាមសំពៅត្រូវឡេសំពៅថ្ងៃ-យប់ទើបដល់. តែពេលខ្លះទៅសំពៅផងដែល ហើយគេឆ្លងកាត់តាមកំពង់ខ្លងត្រីឈ្មោះ ឧទ្ទិយារដ្ឋ តែ៧ថ្ងៃក៏ដល់. (ឯកនិបាតអដ្ឋកថាត្រង់ជម្ពូ-ទីបបេយ្យាល) ។

មហិន្ទត្ថេរសម្ដែងធម៌ប្រោសញោមស្រីបានសម្រេចស្រោតា និងកណ្ឌុកឧ-បាសកជាក្មួយជីដូនមួយរបស់លោក ក៏បានសម្រេចអនាគាមិផលក្នុងពេលនោះដែរ ។

មាតាលោកបានកសាងវត្តមួយឈ្មោះ វេទិសមហាវិហារ ប្រគេនព្រះសង្ឃទាំងនេះគង់, លោកគង់នៅវត្តនេះអស់រយៈកាលចំនួន ៦-៧ ខែ ទើបព្រះឥន្ទមកប្រគេនពត៌មានថា : គួរនិមន្តទៅលង្កាទ្វីបចុះ ព្រោះឱកាសល្អហើយ នោះមហិន្ទត្ថេរ និងអរហន្ត ៤ រូបទៀត ក៏លាញោមស្រីហើយយកទាំងកណ្ឌុកឧបាសកជាក្មួយជីដូនមួយនោះហោះទៅលង្កាទ្វីប លោកទៅសំ-ចតនៅលើភ្នំចេតិយគិរី នាបូព៌ាទិសក្រុងអនុរាធបុរីឯណោះ (មហិន្ទត្ថេរបួសបាន ១២ វស្សាហើយ ព.ស. ២៣៦) ។

( ប្រវត្តិពុទ្ធសាសនាខាងជម្ពូទ្វីបចប់ )

៚

# ខ-ប្រវត្តិពុទ្ធសាសនាខាងលង្កាទ្វីប

មុននឹងនិយាយពីប្រវត្តិនៃពុទ្ធសាសនាដែលសោត់អណ្តែតពីជម្ពូទ្វីបទៅដោតចំកណ្តាលកោះលង្កា ហើយជ្រាបចូលទៅក្នុងបេះដូងអ្នកស្រុក ដោយស្នាព្រះឱស្ឋនៃសាស្ត្រាចារ្យឯកនាមមហិន្ទត្ថេរនោះ ។

ក៏គួរនិយាយពីប្រវត្តិនៃលង្កាទ្វីបនេះជាមុនសិនដែរ សូម្បីរឿងនេះជារឿងព្រេងក្តី ក៏គង់ជារឿងគួរស្តាប់ ហើយជាប្រភពនៃពុទ្ធសាសនាផង ទាំងជារឿងគួរចង់ដឹងផង ដោយរឿងនោះមានឧត្តមគតិ និងមនោគមវិជ្ជាផ្នែកពុទ្ធសាសនាដ៏ពិសិដ្ឋណាស់ ។

## ១-លង្កាទីបប្បវត្តិ និងពុទ្ធដំណើរ

ថា : តាំងតែកាលពីព្រេងនាយក្នុងសាសនាព្រះពុទ្ធកកុសន្ធោ លង្កាទ្វីបនេះ ហៅថា ឱជទ្វីប, ព្រះរាជានាមអភ័យ, នគរឈ្មោះអភយបុរៈ, ចេតិយបព៌តឈ្មោះទេវកូដ, ថូបារាមឈ្មោះបដិយារាម ។ ព្រះកកុសន្ធោព្រមទាំងព្រះអរហន្តចំនួន ៤០.០០០ រូប បាននិមន្តទៅទ្វីបនេះមុន ដើម្បីរម្ងាប់នូវបជ្ជរករោគ (រោគចុះរាក) របស់ប្រជាជន, លុះស្ងប់រម្ងាប់ហើយក៏ទ្រង់សម្តែងធម៌ ទ្រង់ចូលនិរោធសមាបត្តិត្រង់ទីពោធិស្ថាន រួចទ្រង់អធិដ្ឋានឲ្យនាងរូបនន្ទាភិក្ខុនី ព្រមទាំងភិក្ខុនីឯទៀតចំនួន ៥០០ រូប និងពួកទេវតាផង នាំស្តេចខេមរាជពីខេមវតីរាជធានីទៅសាកមែកច្រេសជាមហាពោធិព្រឹក្សខាងស្តាំដាក់ក្នុងផើងមាសយកមកថ្វាយស្តេចអភ័យ ដាំទុកក្នុងឧទ្យានឈ្មោះមហាមេឃវននាទ្វីបនេះ ។

ព្រះកកុសន្ធទ្រង់ប្រទានធម្មក្រក (សំពត់ត្រងទឹក) ឲ្យបញ្ចុះទុកក្នុងបដិឃរាមចេតិយ និងទុកសាវកនាមមហាទេវត្ថេរ ព្រមទាំងភិក្ខុ ១.០០០ រូប ឲ្យទៅប្រដៅប្រជាអ្នកកោះនេះតទៅទៀត ព្រះអង្គត្រឡប់មកជម្ពូទ្វីបវិញ ។

លុះសាសនាព្រះកោនាគមន៍ ទ្វីបនេះប្រែឈ្មោះថា វរទ្វីប, ព្រះរាជានាម សមិទ្ធិ, នគរឈ្មោះ វឌ្ឍមានៈ, ចេតិយបពិតឈ្មោះ សុវណ្ណកូដ ។

ព្រះពុទ្ធអង្គនេះ ព្រមទាំងអរហន្តចំនួន ៣០.០០០ រូប បាននិមន្តទៅទ្វីបនេះម្តង ដើម្បីរម្ងាប់នូវទុរ្ភិក្ស, លុះរម្ងាប់ហើយ ក៏ទ្រង់សម្តែងធម៌ ទ្រង់ចូលនិរោធសមាបត្តិត្រង់ទីពោធិស្ថាន ហើយទ្រង់ព្រះចិន្តាឲ្យកណកទត្តាភិក្ខុនី ព្រមទាំងភិក្ខុនីឯទៀតចំនួន ៥០០ រូប និងពួកទេវតាផង នាំព្រះបាទសោភរាជពីសោភរាជធានីទៅសាកមែកឧទុម្ពរព្រឹក្សជាមហាពោធិព្រឹក្សខាងស្តាំដាក់ក្នុងផើងមាស ដង្ហែយកមកថ្វាយស្តេចសមិទ្ធ ដាំទុកក្នុងឧទ្យានឈ្មោះមហាមេឃវននាទ្វីបនេះ ។ រួចទ្រង់ទុកមហាសុមត្ថេរ ព្រមទាំងភិក្ខុ ១.០០០ រូប និងទ្រង់ប្រទាននូវកាយពន្ធន៍ (វត្ថពន្ធចង្កេះ) ឲ្យបញ្ចុះទុកក្នុងសុវណ្ណកូដចេតិយនោះផង ព្រះអង្គត្រឡប់មកជម្ពូទ្វីបវិញ ។

លុះសាសនាព្រះពុទ្ធកស្សប ទ្វីបនេះហៅថា មណ្ឌទ្វីប វិញ, ព្រះរាជានាម ជយន្តៈ, នគរឈ្មោះ វិសាលៈ, ចេតិយបពិតឈ្មោះ សុភកូដ ។

ព្រះពុទ្ធកស្សប ព្រមទាំងអរហន្តចំនួន ២០.០០០ រូប បាននិមន្តទៅទ្វីបនេះម្តង ដើម្បីរម្ងាប់នូវមហាវិវាទ (ជម្លោះធំ) របស់ប្រជាជន, រួចទ្រង់សម្តែងធម៌ ចូលនិរោធសមាបត្តិត្រង់ទីពោធិស្ថាន, រួចទ្រង់អធិដ្ឋានឲ្យនាងសុធម្មាភិក្ខុនី ព្រមទាំងភិក្ខុនីឯទៀតចំនួន ៥០០ រូប និងពួកទេវតាផង នាំ

ព្រះបាទព្រហ្មទត្តពីពាកណសីកផដាទី ទៅសាកមែកជ្រៃជាមហាពោធិព្រឹក្ស ខាងស្តាំ ដាក់ក្នុងផើងមាសដង្អែយកមកថ្វាយស្តេចដយទ្ធៈដាំទុកជាសក្ខីភាព ក្នុងមហាមេឃវនឧទ្យានទាទ្វីបនេះ ។ រួចព្រះពុទ្ធកស្សប ទ្រង់ទុកសាវកនាម សព្វនន្ទិត្ថេរ ព្រមទាំងភិក្ខុ ១.០០០ រូប ឲ្យនៅក្នុងកោះនេះ ។ ហើយទ្រង់ ប្រទានទូវនទកសាដក (សំពត់ស្រង់ទឹក) ឲ្យបញ្ចុះទុកក្នុងចេតិយឈ្មោះ សុ-កកូដនោះផង ព្រះកស្សបទ្រង់ត្រឡប់មកជម្ពូទ្វីបវិញ ។

លុះសម័យព្រះគោតម ទ្វីបនេះហៅថា លង្កាទ្វីប ឬ តម្ពបណ្ណិទ្វីប (កោះរបស់មនុស្សដែលមានបាតដៃប្រឡាក់សុទ្ធដីក្រហម) ហើយនៅជាព្រៃ មានសុទ្ធតែយក្សបិសាច មិនមានមនុស្សនៅទេ, លុះក្នុងឆ្នាំដែលព្រះពុទ្ធអង្គ នេះបរិនិព្វាន ទើបមានអាទិភជមួយនាម វិជ័យកុមារជាបុត្រសីហពាហុ មក តាំងនគរសោយរាជ្យក្នុងទ្វីបនេះ ។

តមកហៅថា សីហលទ្វីប (កោះដែលវិជ័យកុមារជាបុត្រសីហពាហុ មកនៅកាន់កាប់) នគរឈ្មោះ អនុរាធបុរី, ចេតិយបពិតឈ្មោះមិស្សកចេតិយ ឬ ចេតិយគិរី ។

ព្រះគោតមនេះមុនទីងបរិនិព្វាន បាននិមន្តទៅទ្វីបនេះ ៣ លើកគឺ :

-លើកទី១ : និមន្តទៅតែមួយអង្គឯង ទ្រង់ឈរលើអាកាសចំកណ្តាលទីប្រ-ជុំយក្សបិសាច និងចំកណ្តាលកោះផង ទើបបណ្តាលឲ្យភ្លៀងខ្យល់យ៉ាងខ្លាំង ធ្វើឲ្យយក្សបិសាចរន្ធត់រញ៉េរញ៉ៃ ត្រាតែមកសុំចុះចាញ់ប្រគេនទ្វីបទាំងមូល នេះមកព្រះអង្គដោយទ្រង់យល់ថា : សាសនាព្រះអង្គនឹងមកប្រតិស្ឋានក្នុង ទ្វីបនេះ ទើបទ្រង់ធ្វើវក្កកម្មគឺ និមន្តចូលទ្វីបអស់វារៈ ៣ ដុំ ដែលមាន បណ្តោយចំនួន ៣ យោជន៍ និងទទឹងប្រមាណ ១ យោជន៍ វាតទឹកនៅទីនេះ

ទុកឲ្យមនុស្សនៅ, ហើយទ្រង់ប្រទានទូវទីលាមលុកេសធាតុ (កេសធាតុមិនមានមន្ទិលមានពណ៌ខៀវ) ដល់ពួកយក្សបិសាចនោះ ក្នុងខែទី៩ អំពីបានត្រាស់ ។

-លើកទី២ : ក្នុងឆ្នាំទី៥ អំពីបានត្រាស់ទ្រង់និមន្តទៅម្តងទៀត ដោយទៅម្នាក់ឯង ដើម្បីទូន្មាន និងសម្រុះសម្រួលស្តេចនាគទាំងពីរឈ្មោះ ចូឡោទរៈ និងមហោទរៈ ជាមា និងក្មួយទាស់គ្នាពីមណិបល្ល័ង្ក ។

-លើកទី៣ : ក្នុងឆ្នាំទី៨អំពីបានត្រាស់ទ្រង់និមន្តទៅជាមួយនឹងភិក្ខុចំនួន៥០០រូប ដោយមណិអក្ខិនាគរាជអារាធនា ហើយទ្រង់ចូលនិរោធសមាបត្តិត្រង់មហាចេតិយដ្ឋាន និងថូបារាមចេតិយដ្ឋានជាដើម រួចទ្រង់ទុកស្នាមព្រះបាទលើភ្នំសុមនកូដផង ហើយទ្រង់ត្រឡប់មកជម្ពូទ្វីបវិញ ។

## ២-ខត្តិយវង្សលង្កាទ្វីបក្រុងអនុរាធបុរី

១-ក្នុងឆ្នាំដែលព្រះសម្ពុទ្ធបរិនិព្វាននោះ អាទិរាជនាម វិជ័យកុមារ ជាបុត្រសីហពាហុ ក៏មកកសាងនគរតាំងនៅក្នុងកោះនេះដែរ ។

វិជ័យកុមារ(៨)នេះ សោយរាជ្យបាន៣៨ឆ្នាំ ហើយសុគតក្នុងឆ្នាំទី១៤

(៨) វិជ័យកុមារនេះជាពូជថ្នាំ ក្លឹង្គ. ថា : មុនពុទ្ធកាល ស្តេចក្លឹង្គនាមវង្គៈ និងព្រះនាងកាលិង្គរាជធីតាក្នុងវង្គនគរ មានបុត្រីមួយនាមដូចមាតាដែរ ហោរាទាយថា បុត្រីនេះនឹងបានសត្វរាជសីហ៍ជាប្តី មាតាបិតាអៀនខ្មាស ក៏និរទេសបុត្រីនេះចេញ បុត្រីនេះបានដោយសារនឹងពួករទេះ ទៅជួបនឹងរាជសីហ៍បានគ្នាជាប្តីប្រពន្ធ បានបុត្រមួយនាមសីហពាហុ និងបុត្រីមួយនាមសីហសិម្ពលី លុះកុមារនេះអាយុ ១៦ ឆ្នាំ ក៏មាតា និងប្អូនស្រីរត់មកស្រុកជីដូនជីតា សេនាបតីម្នាក់បានយកមាតារបស់កុមារ-កុមារិកានេះជាភរិយា ក្រោយនេះរាជសីហ៍មកតាម ស្តេចជីតាឱ្យសីហពាហុជាចៅចេញតយុទ្ធ រាជសីហ៍ភ្ញាក់មាត់ប្រមាថកូនឯងត្រូវសរស្លាប់. រួចគេលើកសីហពាហុធ្វើស្តេច តែកុមារនេះបានប្រគល់រាជសម្បត្តិថ្វាយមាតាវិញ. មាតាបានផ្សំបុត្រ-ធីតាជាស្វាមីភរិយា។ថ្មីនេះព្រមទាំងពលខ្លះ ក៏លាមាតាមកសាងបុរីថ្មី ត្រង់ទីដែលរាជសីហ៍ជាបិតាខ្លួននោះនៅ បុរីថ្មីនេះឈ្មោះ សីហបុរីរហូតមក។ ក្សត្រពីរនាក់បងប្អូននេះមានបុត្រ ៣២ រូប មានវិជ័យកុមារនេះជាដើម ដោយវិជ័យកុមារមានអាចារៈមិនសុវណ្ណ គេស្អប់ច្រើន. (ឆ្លង...)

នៃរជ្ជកាលព្រះបាទឧទយភទ្ទនាជម្ពូទីប (ព.ស. ៣៨) ។

២-បណ្ឌុកាសុទេវរាជាក្មួយវិជយកុមារ សោយរាជ្យក្នុងឆ្នាំទី១៥ នៃរជ្ជកាលព្រះបាទឧទយភទ្ទនាជម្ពូទីប ។ អគ្គមហេសីស្ដេចនេះនាមព្រះនាងភទ្ទកាញ្ចនាជាចៅអមិតោ្តទនសាក្យៈ, ស្ដេច និងព្រះនាងនេះមានបុត្រ១០ រូប និងបុត្រីមួយផង, សោយរាជ្យបាន ៣០ ឆ្នាំ ហើយសុគតក្នុងឆ្នាំទី២០ នៃរជ្ជកាលព្រះបាទនាគទស្សកៈក្នុងជម្ពូទីប (ព.ស. ៦៨) ។

៣-ក្នុងឆ្នាំទី ២០ នោះ អភ័យកុមារជាបុត្របណ្ឌុកាសុទេវរាជ សោយរាជ្យតមកទៀតអស់រយៈ ២០ ឆ្នាំ ហូតដល់ឆ្នាំទី១៧ នៃរជ្ជកាលព្រះបាទសុសុនាគ នាជម្ពូទីប (ព.ស. ៨៨) ។

៤-ក្នុងឆ្នាំទី ២០ នៃរជ្ជកាលអភ័យកុមារនោះ មានទាមិកនាម បណ្ឌុកាភ័យ ជាក្មួយច្បាំងដណ្ដើមយករាជ្យ ។ បណ្ឌុកាភ័យ(៥)នេះ ធ្វើស្ដេច

---

មាតាបិតាក៏និរទេសចេញជាមួយនឹងបរិវារ ៧០០ នាក់ ព្រមទាំងភរិយា និងកូនក្មេងស្រីប្រុសប៉ុណ្ណោះដែរ ឱ្យកោរឡៅក្បាលដាក់ក្នុងសំពៅនីមួយៗជាពួកៗ បណ្ដែតចោលក្នុងសមុទ្រទៅ ។ សំពៅកូនក្មេងអណ្ដែតទៅជាប់នឹងនគ្គទីប (កោះស្រីលង្កា). សំពៅស្រីៗជាភរិយាអណ្ដែតទៅជាប់នឹងមហិឡាទីប (កោះស្រីវិជ័យ-ជ្វាសុមាត្រា). ឯសំពៅវិជ័យកុមារទៅជាប់នឹងលង្កាទីប (កោះដែលគេលោតឡើងពីសំពៅទៅនៅ) ។ វិជ័យកុមារបានយកស្រីយក្សកុមារជាមេកោះនោះឈ្មោះនាង កុវេណា ជាភរិយា បានបុត្រមួយនាម ជីវហត្ថ និងបុត្រីមួយនាម សល្លនាមិកា. ដោយវិជ័យកុមារប្រុងរៀបអភិសេកអគ្គមហេសីថ្មីទៀត ក៏លែងនាងកុវេណាចោល នាងនេះនាំកូនពីរនាក់ដើរក្នុងកោះគេវាយនាងស្លាប់ ឯកូនពីរនាក់គេចខ្លួនរួច កូនទាំងពីរនាក់នេះបានយកគ្នាជាប្ដីប្រពន្ធ មកនៅក្នុងមលយជនបទ (ជ្វាមាលយូ) ។

(៥) ស្ដេចនេះជាបុត្រនាងចិត្តកា និងអយ្យបុត្រនាម ទីឃគាមណី. ថា : នាងចិត្តកានេះជាបុត្រីពៅរបស់ស្ដេចបណ្ឌុវាសុទេវរ៉ា និងព្រះនាងភទ្ទកាញ្ចនា ។ ហោរាទាយថា : នាងពៅនេះបើមានបុត្រៗនោះនឹងសម្លាប់ឪពុកធំយករាជ្យ.នោះបងៗទាំង៩នាក់រកលេសសម្លាប់នាងពៅ តែអភ័យកុមារជាបងច្បងមិនព្រម ។ គេឱ្យនាងពៅនៅតែក្នុងប្រាសាទសសរមួយ និងស្រីគមម្នាក់នៅរក្សា ។ មនុស្ស ១០០ នាក់យាមជុំវិញ មានតែទ្វារមួយចេញមកបន្ទប់ស្ដេច ។ ថា : ទីឃគាមណីជាក្មួយមាតានាងពៅនេះបានទៅនៅគាល់ស្ដេច.

(ឆ្លង...)

*បាន ១៧ ឆ្នាំ រហូតដល់ឆ្នាំទី ១៦ នៃរជ្ជកាលព្រះបាទកាឡាសោកទាជម្ពូទ្វីប ហើយ ១ ឆ្នាំ ខាងក្រោយផងជា ១៨ (ធ្វើស្តេចមិនមានគេអភិសេក), សោយរាជ្យបាន ៧០ ឆ្នាំទៀត ហើយសុគតក្នុងឆ្នាំទី១៤ នៃរជ្ជកាលព្រះបាទ*

---

ដោយស្រីគមឱ្យការផង យប់ៗគេជិះយន្តក្តាមចូលតាមតន្ទឹះទ្វារទៅរួមសំវាស និងនាងពៅទាល់តែមានគភ៌. មាតា-បិតានាងពៅឥតយកទោសទេ តែបងៗទាំង ៩ ថា : បើកូននាងពៅប្រុសសម្លាប់ចោល ។ ថា : ស្វាមីនាងពៅឱ្យមនុ-ស្សពីរនាក់មករក្សា បងៗ៩នាក់ឱ្យគេសម្លាប់មនុស្សពីរនេះៗស្លាប់ទៅកើតជាយក្សតាមរក្សាបុត្រនាងពៅទៀត ។ ថា គេប្តូរបុត្រនាងពៅ និងបុត្រីស្រីម្នាក់ក្នុងមន្ទីរពេទ្យបណ្តោះអាសន្ន។ ថា : ពេលនោះបិតានាងពៅសុគត ហើយឱ្យអភ័យកុមារជារាមច្បងសោយរាជ្យ ។ ថា : នាងពៅឱ្យទាសីយកបុត្រនាងដាក់ក្នុងល្អុតយកទៅលាក់ស្រុកក្រៅ ទាសីនេះទៅប្រទះនឹងបងៗទាំង ៩ កំពុងប្រពាតព្រៃតេហៅផែក ។ ឯយក្សពីរដែលតាមរក្សាទារក-និម្មិតជាជ្រូក. បងៗទាំង ៩ នោះដេញបាញ់ជ្រូក ទាសីក៏យកទារកគេទៅផ្ញើនឹងនាយស្មៀនៗ ឃោសនាថា ប្រពន្ធគេសម្រាលកូនភ្លោះ ។ លុះបុត្រនាងពៅនេះអាយុ ៧ ឆ្នាំ ទៅមុតទឹកនឹងក្មេងៗ បងនាងពៅស៊ើបដឹង បញ្ជាឱ្យសម្លាប់ក្មេងៗអស់ ឯកូននាងពៅពួនក្នុងស្រះនាឡទ្រណើមួយរួចខ្លួន. ក្រោយនេះបងនាងពៅបញ្ជាឱ្យនាយគោបាលបញ្ឆោតបុត្រនាងពៅទៅរកភ្លើងឯផ្ទះ កុមារនេះមកប្រើកូនស្មៀន បន្តមកទៀត គេស្មានខុសសម្លាប់កូនស្មៀននោះទៅ ។ លុះអាយុ ១៦ ឆ្នាំ នាងពៅលបបញ្ជូនប្រាក់ទាំងពាន់ៗឱ្យនាយស្មៀនរក្សា និងឱ្យបុត្រនេះទៅរៀនក្នុងសំណាក់មណ្ឌលព្រាហ្មណ៍ជាមួយនឹងចន្ទ-កុមារជាកូនព្រាហ្មណ៍នោះ ។ ថា : ព្រាហ្មណ៍នេះបានចំណាយប្រាក់ និងកេណ្ឌទ័ពឱ្យបាន ៥០០ នាក់រួចថ្លៃថា : បើរាជកុមារប្រទះស្រីក្រមុំណាកាន់ស្លឹកឈើៗនោះក្លាយជាមាស អ្នកយកនាងនេះជាភរិយាចុះ រួចតាំងចន្ទកូនខ្ញុំនេះជាបុ-រោហិត ។ បុត្រនាងពៅនេះកេណ្ឌទ័ពបានច្រើនទៀត រួចត្រៀមក្បែរគិរីកណ្ណកបពិត. ទំនុកៗ នាងសុវណ្ណបាលិជាបុត្រីគិរិកណ្ណសីវៈ ដែលជាឪពុកធំតេនោះគង់យានមកហើយ គេស្ទុះទៅស្ទាក់មុខយានសួរនាម និងការណ៍សព្វគ្រប់ រួចគេសុំភត្តដែលនាងបម្រុងយកទៅថ្វាយបិតាឯស្រែនោះ នាងដាក់ភត្ត និងភាជន៍មាសឱ្យ. យកស្លឹកជ្រៃមកដាក់ភត្តឱ្យពលនោះទៀត នោះស្លឹកឈើក្លាយទៅជាមាសទាំងអស់ រួចគេនាំនាងនេះតេចពីទីនេះទៅ ។ បិតានាងនេះបញ្ជាឱ្យមនុស្ស និងកូនប្រុស ៥ នាក់ទៅតាម តែនាយចន្ទពិឃាដអស់. លើកតែអភ័យរាជចេញ បងនាងពៅទាំងអស់សុទ្ធតែចេញតយុទ្ធ តែមិនមានជ័យជំនះ ។ ពួកគេចោទស្តេចបងៗថា : ប្រើរហស្សបាយជាមួយនាងពៅ គេរកលេសពិឃាដស្តេចបងៗ ក៏ដាក់រាជ្យឱ្យអនុជទាំងនោះ. ក្រោយនេះបិតានាងសុវណ្ណបាលិឈប់ចូលនឹងបងប្អូន ៨ នាក់ហើយ. ឯបណ្ឌុកាភ័យជិះលាយក្សចូលតយុទ្ធឪពុកធំទាំង ៨ ស្លាប់អស់ ។ ទ្រង់ឱ្យលាងស្វេត្រឆ័ត្រយកទឹកមកអភិសេកខ្លួន និងនាងសុវណ្ណបាលិ រួចតាំងអភ័យរាជជានគរបាល. ប្រទានគិរីកណ្ណកជនបទដល់ឪពុកក្មេក. នាទីបុរោហិតដល់នាយចន្ទ. ឋានន្តរស័ក្តិដល់ពួកពល ។

ចន្ទគុត្តនាជម្ពូទ្វីប (ព.ស. ១៧៦) ។

៥-ព្រះបាទមុដ្ឋសិវៈជាបុត្របណ្ឌុកាភ័យ និងព្រះនាងសុវណ្ណបាលិ មុដ្ឋសិវៈនេះ មានបុត្រ ១០ រូប និងបុត្រី ២ រូប សោយរាជ្យបាន ៦០ ឆ្នាំ ហើយសុគតក្នុងឆ្នាំទី ១៧ នៃរជ្ជកាលអសោក នាជម្ពូទ្វីប (ព.ស. ២៣៦) ។

៦-ព្រះបាទទេវានម្បិយតិស្សៈជាបុត្រទី២ នៃព្រះបាទមុដ្ឋសីវៈ សោយរាជ្យក្នុងឆ្នាំទី៨ នៃរជ្ជកាលអសោក (ព.ស. ២៣៦) និង ១ ខែ) ។ តាមអនុសាស្រ្តនៃខត្តិយវង្សនេះបណ្ឌិតត្រូវយល់ថា : ព្រះសម្ពុទ្ធបរិនិព្វាន បាន ២៣៦ ឆ្នាំ ទើបព្រះមហិន្ទត្ថេរទៅប្រតិស្ឋានពុទ្ធសាសនាក្នុងលង្កាទ្វីប ។

## ៣-ធាតុនិធាន និងសាសនារបស់ព្រះគោតម

មែនពិត ពេលដែលព្រះមហិន្ទត្ថេរ និងសមាជិក ៦ រូបទៀតហោះទៅដល់លង្កានោះ ព្រះបាទទេវានម្បិយតិស្សៈ[១០] ទើបរាជាភិសេកបាន១ខែប៉ុណ្ណោះ ។ ស្តេចនេះ និងអសោកជាមិត្រជិតស្និទ្ធ ប៉ុន្តែមិនដែលបានជួបគ្នាផ្ទាល់ទេ គ្រាន់តែផ្ញើបណ្ណាការថ្វាយគ្នាទៅវិញទៅមក ស្តេចនេះមានបុញ្ញានុ-

(១០) ថា : ពីអតីតកាលមានបងប្អូន ៣ នាក់ជាឈ្មួញទឹកឃ្មុំគឺ បងពីរនាក់ជាអ្នកដឹកនាំមកឱ្យ, ប្អូនពៅជាអ្នកលក់។ គ្រានោះមានព្រះបច្ចេកពុទ្ធមួយអង្គទៅរកទឹកឃ្មុំមកធ្វើថ្នាំ បានជួបនឹងនាងកុម្ភទាសី (ឈ្នួលស្រីដងទឹក) ម្នាក់, នាងចង្អុលប្រាប់ថា : សូមព្រះគុណម្ចាស់និមន្តទៅរកអ្នកលក់ទឹកឃ្មុំឯណោះចុះ បើគេប្រគេនឬមិនប្រគេនឬគេថាដូចម្តេច លុះវិលមកវិញប្រាប់ខ្ញុំករុណាផង។ ឯអ្នកលក់ទឹកឃ្មុំប្រគេនទាល់តែពេញហូរហៀរបាត្រ រួចប្រាថ្នាថា : សូមឱ្យបានជាស្តេចឯករាជ្យមានអំណាចទៅលើអាកាស និងក្នុងដីចំនួន ១ យោជន៍, លោកថា : សូមឱ្យក្តីប្រាថ្នានេះបានសម្រេចចុះ។ អ្នកលក់ទឹកឃ្មុំនេះ លុះមកផ្ទះប្រាប់បងទាំងពីរឱ្យអនុមោទនា, បងច្បងខឹងថា : សូម្បីជនចណ្ឌាលក៏ចេះស្លៀកពាក់សំពត់កាសាវពស្រ្តដែរ ក្រែងជនទទួលទឹកឃ្មុំពីប្អូនឯងទៅនោះជាជនចណ្ឌាលណាគេទៅស្រុកចណ្ឌាលបាត់ហើយទេដឹង? ឯបងកណ្តាលខឹងថា : ប្អូនឯងទៅចាប់ព្រះបច្ចេកពុទ្ធនោះបោះចោលក្នុងត្រើយនាយសមុទ្រ។ ប៉ុន្តែក្រោយភ្លាមនោះបងទាំងពីរបានស្តាប់ទានានិសង្សដែលប្អូនពៅនិយាយប្រាប់ ក៏អនុមោទនាយកដោយរីករាយ។ ឯព្រះបច្ចេកពុទ្ធលុះបានទឹកឃ្មុំហើយ ក៏វិលមកជួបនឹងនាងកុម្ភទាសី ប្រាប់តាម... (ឆ្លង...)

កាលជិតប្រហែលអសោកដែរ ។ ថា : មានដើមឫស្សី ៣ ដើមប្រមាណប៉ុនដងទង់ជ័យ កើតសម្រាប់ស្ដេចនេះគឺ :

១-ឈ្មោះលតាយដ្ឋិ ដើមមានពណ៌ចេញមកជាប្រាក់ ឯមែកចេញមកជាមាស,

២-ឈ្មោះបុប្ផយដ្ឋិ មានផ្កា ៥ ពណ៌ ហើយមានកេសរជ្រុះកាយកាយក្រអូបឈ្ងុយឈ្ងប់,

៣-ឈ្មោះសកុណយដ្ឋិ មើលទៅដូចជាសត្វចតុបាទ និងរូបភាពនៃសត្វស្លាបឯទៀត មានហង្ស-មាន់-ព្រហ៊ិតជាដើម, ហើយមានរតនជាតិជាអនេកអនេកអនន្តកើតសំម្រាប់ស្ដេចនេះផង ។

សម័យដែលរាជាភិសេករួចបាន ១ ខែ ស្ដេចនេះបានយាងទៅក្រសាលព្រៃភ្នំចេតិយគិរី ជួបនឹងព្រះមហិន្ទត្ថេរក្នុងព្រៃភ្នំនោះ ។

មហិន្ទត្ថេរ....មហារាជ ! មានជនជាសាច់ញាតិមកច្រើនដែរឬ ?

ព្រះរាជា....ទានប្រោសមានច្រើនដែរ !

មហិន្ទត្ថេរ....ចុះបើលះបង់សាច់ញាតិនោះទៅ មានជនណាដទៃមិនមែនជាសាច់ញាតិដែរឬ ?

---

ដំណើរដែលអ្នកលក់ទឹកឃ្មុំប្រាថ្នា នោះនាងកុម្ភទាសីយកក្រមាថ្មីមួយដែលខ្លួនដណ្ដប់ប្រគេនរួចប្រាថ្នាថា : ដោយអានុភាពនៃវេយ្យាវច្ចកម្ម និងចីវរទាននេះ ខ្ញុំករុណាសូមឱ្យមានរូបសម្បត្តិល្អបំផុត ព្រមទាំងយសសក្តិ និងសម្បត្តិដ៏ពិសិដ្ឋ បើអ្នកលក់ទឹកឃ្មុំនោះបានជាស្ដេចចុល្លចក្រ សូមឱ្យខ្ញុំបានជាអគ្គមហេសីស្ដេចនោះកុំខាន លោកថា : សូមឱ្យក្ដីប្រាថ្នានេះបានសម្រេចចុះ ។ បងច្បងគឺនិគ្រោធសាមណេរ (ដោយទោសប្រមាថព្រះបច្ចេកពុទ្ធថា "ជនចណ្ឌាល, បានជាសាមណេរនេះទៅប្រសូតក្នុងស្រុកចណ្ឌាល"), បងកណ្ដាលគឺ ស្ដេចទេវានម្បិយតិស្ស: (ដោយទោសពោលពាក្យទ្រគោះបោះបោកទៅព្រះបច្ចេកពុទ្ធថា ចាប់បោះចោលក្នុងត្រើយនាយសមុទ្រ, បានជាស្ដេចនេះកើតក្នុងកោះលង្កា), ប្អូនពៅជាអ្នកលក់ទឹកឃ្មុំ គឺ អសោក, ឯនាងកុម្ភទាសីគឺ ព្រះនាងអសន្ធិមិត្តា ។

ព្រះរាជា....ទានប្រោសជនមិនមែនជាសាច់ញាតិ មានច្រើនណាស់!

មហិន្ទត្ថេរ...ចុះបើលះបង់សាច់ញាតិ និងលះបង់ជនមិនមែនជាញាតិទៅ តើមានជនដទៃណាមួយទៀតដែរឬទេ ?

ព្រះរាជា...ទានប្រោសមានតែខ្ញុំករុណាហ្នឹងឯង !

មហិន្ទត្ថេរ...ប្រពៃណាស់មហារាជ ! ធម្មតាខ្លួនយើងថាជាសាច់ញាតិរបស់ខ្លួនក៏មិនមែន ថាមិនមែនជាសាច់ញាតិរបស់ខ្លួនក៏មិនមែន (គឺខ្លួនត្រូវទីពឹងខ្លួន) ។ រួចលោកសម្តែងចូឡហត្ថិបទោបមសូត្របន្តទៀតឲ្យស្តេច និងសេនាមាត្យចំនួន៤០.០០០នាក់បិតក្នុងសរណគមន៍ និងសីល៥ទាំងអស់។

ព្រះរាជាជ្រះថ្លាណាស់ ក៏ទូលនិមន្តទៅទីក្រុង តែមហិន្ទត្ថេរមិនទាន់ព្រមនិមន្ត ។

អញ្ជើញស្តេចខ្ញុំករុណាឲ្យយករថមកទទួល ហើយថ្វាយបង្គំលាទៅ។

រាត្រីនោះ ព្រះមហិន្ទត្ថេរបញ្ជាឲ្យសុមនសាមណេរឃោសនាធម៌លោកនេនទេះក៏ចូលចតុត្ថជ្ឈាន អធិដ្ឋានឲ្យអ្នកលង្កា និងទេវតា-គ្រុឌ-នាគព្រមទាំងព្រហ្មលោកបានឮសម្លេងប្រកាសធម៌នោះទាំងអស់ ។

ព្រលឹមស្រាងឡើង គេឃើញសារថីបររថទៅនិមន្តព្រះថេរៈទាំងឡាយនោះ ។ ព្រះថេរៈទាំងនោះថា : ចូរសារថីទៅចុះ អាត្មាភាពនឹងទៅតាមក្រោយ ។

ស្រាប់តែអរហន្តទាំងនោះ ហោះមកដល់បឋមចេតិយក្បែរទីក្រុងមុនសារថីនោះ ។ មហាស្ចារ្យនេះនាំឲ្យស្តេច និងអ្នកក្រុងរីតតែជ្រះថ្លា និងស្ញើចយ៉ាងខ្លាំង ។

ព្រះរាជាលុះថ្វាយបង្គំហើយ ក៏និមន្តទៅក្នុងព្រះរាជនិវេសន៍ លុះ

អង្គាសចង្ហាន់រួច មហិន្ទត្ថេរសម្ដែងនូវសេចក្ដីយុត្ត, លុះចប់ធម្មទេសនានោះ មានស្ត្រី ៥០០ នាក់ បានសម្រេចស្រោតាបត្តិផល, ហើយសម្ដែងទេវទូត-សូត្រទៀត លុះចប់ មានមហាជនចំនួន ១.០០០ នាក់ បានសម្រេចស្រោ-តាបត្តិផលដែរ ។

ព្រះរាជាទ្រង់ទុកមហាមេឃវនុយ្យាន ជាអាវាសសម្រាប់សំចតនៃព្រះអរហន្តទាំងនោះ ។

លុះថ្ងៃទី៧ ក៏និមន្តទៅចេតិយគិរីវិញ ចាំវស្សានៅទីនោះ នាថ្ងៃចូលវស្សានោះ មានសេនាមាត្យឈ្មោះមហាអរិដ្ឋ ព្រមទាំងបងប្អូន ៥៥ នាក់ បួសក្នុងសំណាក់ព្រះថេរៈ, ហើយបានសម្រេចព្រះអរហន្តក្នុងរោងខុរគ្គកិច្ចទាំងអស់ ។

ក្នុងវស្សានោះមានព្រះអរហន្តចំនួន ៦២ អង្គ ។

លុះថ្ងៃពេញបូណ៌មីកត្តិកចេញវស្សាហើយ មហិន្ទត្ថេរធ្វើកិច្ចថា : អាត្មាភាពទាំងឡាយចង់ត្រឡប់ទៅជម្ពូទ្វីបហើយ ព្រោះរលឹកព្រះសម្ពុទ្ធណាស់ !

ព្រះរាជា...ចុះក្រែងព្រះសម្ពុទ្ធទ្រង់បរិនិព្វានហើយឬ ?

មហិន្ទត្ថេរ...ព្រះសម្ពុទ្ធបរិនិព្វានមែន ! ប៉ុន្តែព្រះសារីរិកធាតុរបស់ព្រះអង្គឋិតនៅឡើយ ។

ទេ ! ខ្ញុំករុណាចង់និមន្តព្រះសារីរិកធាតុមកប្រតិស្ឋានក្នុងកោះនេះ តែមិនដឹងជាបានព្រះសារីរិកធាតុនោះពីទីណា ?

មហិន្ទត្ថេរ...បើព្រះបំណងល្អដូច្នោះ សូមទ្រង់ពិគ្រោះក្យានឹងសុមន-សាមណេរមើល៍ ?

សុមនសាមណេរ...........សូមទ្រង់ដោតទង់-ឆ័ត្រឲ្យព្រោងព្រាតចុះ, សូមសមាទានឧបោសថ, សូមរៀបចំជីរមន្ទិល និងស្វេតឆ័ត្រ និងទីប្រជុំជន, ជម្រះវិថីឲ្យស្អាតល្អ, រួចថ្ងៃសៀលសូមទៅរង់ចាំក្នុងមហាមេឃវនុយ្យានចុះ, នោះទ្រង់នឹងបានទូវព្រះសារីរិកធាតុមិនខាន ។

ដោយបានទទួលព្រះថេរដីកាពីលោកអ៊ុំស្រេចហើយ សុមនសាម-ណេរនេះក៏ហោះទៅជួបព្រះអសោកជាជីតា សុំព្រះសារីរិកធាតុទាំងឡាយ បានហើយក៏ហោះទៅជួបព្រះឥន្ទសុំព្រះទក្ខិណអក្ខកធាតុ (ដង់កាំបិតស្តាំ)បាន ទៀត ហើយត្រឡប់ទៅដល់ចេតិយគិរីលង្កាវិញភ្លាម ។

គ្រានោះ អរហន្តព្រមទាំងស្តេច-ប្រជាជន-ទេវតា រៀបក្បួនដង្ហែ ព្រះនោះ អឹកធឹកអស្ចារ្យណាស់, ដោយព្រះរាជាទ្រង់ទូលទូវក្អមផ្កាសម្រាប់ ទ្រព្រះធាតុ ហើយទើបយកទៅដាក់លើពានជីរមន្ទិល, ឯដំរីរករីករាយក៏ ស្រែកកង់រំពងទាំងភ្លេងតូរ្យតន្ត្រីត្រសង្ខក៏បន្លឺយ៉ាងទ្រហឹង មហាមេឃក៏បង្អុរ ភ្លៀងឥតទទឹក, ពសុធាក៏ញ័រដល់បាតសមុទ្រ ។

រួចគេហែជុំវិញទីក្រុង ហើយឆ្ពោះមុខទៅថូបារាមចេតិយ, ស្រាប់តែ ធាតុនោះអណ្តែតពីក្បាលដំរីទៅលើអាកាសចំនួន ៧ ជួរដើមត្នោត សម្តែង នូវបាដិហារ្យគួរឲ្យអស្ចារ្យពន់ពេក ទើបធ្លាក់ចុះមកប្រតិស្ឋានក្នុងបរិភោគ-ចេតិយដ្ឋានរបស់ព្រះពុទ្ធទាំង ៣ អង្គអំពីបុរាណកាលខាងត្បូងក្រុងអនុរ-ធបុរី ។

ដោយក្តីជ្រះថ្លានឹងបាដិហារ្យនេះ គេឃើញអនុជរបស់ស្តេចនាម អភ័យកុមារ ព្រមទាំងបុរសចំនួន ១.០០០ រូប បួសក្នុងពេលនោះភ្លាម, បន្ទាប់មកគេឃើញយុវជនចេញពីទីក្រុង និងក្រៅក្រុងមកបួសជាភិក្ខុមាន

ចំនួន ៣០.០០០ រូបដែរ ។

លុះបូជា និងប្រតិស្ឋានព្រះសារីរិកធាតុរួចហើយ ព្រះមហិន្ទត្ថេរក៏និមន្តទៅចាំវស្សានៅនាឧទ្យានឈ្មោះមហាមេឃវ័ន ។

សម័យនោះ ព្រះនាងអនុឡាទេវីជាអគ្គជាយាកមហេសីរបស់ស្តេចព្រមទាំងនាងកញ្ញាចំនួន ១.០០០ រូបចង់បួស, ព្រះរាជាក៏ស្នើការនេះនឹងព្រះមហិន្ទត្ថេរ ។

ព្រះមហិន្ទត្ថេរក៏បញ្ជាឲ្យស្តេចប្រើអរិដ្ឋអាមាត្យជាក្មួយស្តេច ដែលចង់បួសដែរនោះ ទៅក្រុងបាដលិបុត្រនិមន្តព្រះសង្ឃមិត្តាថេរីមកបំបួសនាងកញ្ញាទាំងនេះ ។

ដោយយកនូវសាសនប័ណ្ណ (សំបុត្រខាងសាសនា) របស់ស្តេចនិងព្រះមហិន្ទត្ថេរទៅផង និងដោយបុញ្ញានុភាពរបស់ព្រះថេរៈផង អរិដ្ឋអាមាត្យទៅកំពង់ជម្ពុកោលៈជិះសំពៅទៅតែ ១ ថ្ងៃប៉ុណ្ណោះ ក៏ដល់ទៅក្រុងបាដលិបុត្រ ។

ទិវាកាលនោះ អរិដ្ឋអាមាត្យបានឡើងគាល់អសោក ហើយសាស័ព្ទនូវពត៌មានសព្វគ្រប់ អំពីវត្ថុបំណងនៃស្តេចរបស់ខ្លួន និងព្រះមហិន្ទត្ថេរ, រួចទើបទៅថ្វាយបង្គំព្រះសង្ឃមិត្តាថេរី និងថ្វាយនូវសាសនប័ណ្ណនោះផង ។

ព្រះថេរីក៏យកសាសនប័ណ្ណនោះ និមន្តទៅអានថ្វាយអសោកជាញោមថា : មហិន្ទត្ថេរជាបង (និងស្តេចក្រុងលង្កា) សូមនិមន្តព្រះសង្ឃមិត្តាថេរីជាប្អូនទៅលង្កាទ្វីប ដើម្បីបំបួសកញ្ញាចំនួន ១.០០០ រូបមានព្រះនាងអនុឡាទេវីជាដើម, ហើយសូមព្រះនាងសុំឲ្យញោមយើងសាកយកនូវមែកពោធិព្រឹក្សទៅជាមួយផង ព្រោះអ្នកលង្កាចង់បានយកទៅប្រតិស្ឋានក្នុងទ្វីប

នេះ ។

ព្រះបាទអសោក...លោកកូនអើយ ! មហិន្ទត្ថេរ និងសុមនសាមណេរ ជាបុត្រ និងចៅខ្ញុំករុណាទៅលង្កាបាត់ ដូចគេកាត់ដៃខ្ញុំករុណាៗ ទីកបុត្រ និងចៅពន់ពេកណាស់ ! ក្ដីក្រៀមក្រំចិត្តរបស់ខ្ញុំករុណាស្ងប់បន្តិច នោះ ដោយមានលោកកូននៅគង់ជិត ណ្ហើយលោកកូនស្រីកុំនិមន្តទៅអី !

ព្រះសង្ឃមិត្តាថេរី... ព្រះថេរដីការបស់បងអាត្មាមានទម្ងន់ណាស់ ទាំងនាងខត្តិយកញ្ញាទាំងឡាយមានអនុឡាទេវីជាដើមចំនួន ១.០០០ រូប ដែលចង់បព្វជ្ជានោះ ក៏រង់ចាំមើលផ្លូវអាត្មាភាពដែរ អាត្មាភាពគួរតែទៅ ។

អសោកថា : អញ្ចឹង លោកកូនស្រីនិមន្តក៏និមន្តចុះ យកព្រះមហាពោធិព្រឹក្សទៅជាមួយផង ។

ចុះព្រះបាទអសោកបានមែកព្រះមហាពោធិព្រឹក្សនេះពីណាមក ?

ថា : ពីមុននោះ តាំងពីសុមនសាមណេរមិនទាន់មកយកព្រះសារីរិកធាតុម៉្លេះ អសោកប្រុងនឹងបញ្ជូនទូវព្រះមហាពោធិព្រឹក្ស ដែលគេមិនគួរកាត់ដោយកាំបិតទៅលង្កាទ្វីបម្ដងហើយ ដោយលោករកឧបាយមិនទាន់ឃើញ ហើយលោកសួរទៅមហាទេវអាមាត្យ ។ អាមាត្យនោះថា ឲ្យសួរព្រះបណ្ឌិតទាំងឡាយ ។

ភិក្ខុទាំងឡាយប្រគល់ការៈនេះឲ្យទៅព្រះមោគ្គលីបុត្តតិស្សត្ថេរៗ ថា បពិត្រមហាបពិត្រមហាកជ ! ការសោកបញ្ជូនមែកព្រះមហាពោធិព្រឹក្សទៅលង្កាទ្វីប គួរពោលនូវអធិដ្ឋានទាំង ៥ តាមបំណាំងរបស់ព្រះភគវតែចុះ ។

តើអធិដ្ឋានទាំង ៥ នោះដូចម្ដេចខ្លះ ?

១-ព្រះភគវាបរមគ្រូពេលទ្រង់សិងលើព្រះក្រឡាបន្ទំមហាបរិនិព្វាន

ទ្រង់អធិដ្ឋានថា បើពេលអសោកមហារាជយាងទៅសាកនូវមែកព្រះមហាពោធិព្រឹក្សទៅប្រតិស្ឋានក្នុងមហាពោធិស្ឋានលង្កាទ្វីប ពេលនោះ សូមមែកមហាពោធិព្រឹក្សខាងស្ដាំដាច់ឯងមកប្រតិស្ឋានក្នុងផើងមាសចុះ ។

២-ទ្រង់អធិដ្ឋានថា បើព្រះមហាពោធិព្រឹក្សនេះប្រតិស្ឋានស៊ប់នៅក្នុងទីនោះហើយ សូមឲ្យភ្លៀងហិមវលាហកៈបង្អុរចុះកុំដាច់ ។

៣-ទ្រង់អធិដ្ឋានថា ក្នុងថ្ងៃទី៧ សូមឲ្យឆព្វណ្ណរង្សីយាងចុះចាកផ្ទៃនៃហិមវលាហកៈ មកប្រតិស្ឋានក្នុងផើងមាស ហើយបញ្ចេញស្លឹក និងផ្លែទាំងឡាយយ៉ាងរយោងរយោង ។

៤-ទ្រង់អធិដ្ឋានថា ក្នុងវត្តថូបារាម សូមព្រះអក្ខកធាតុខាងស្ដាំធ្វើយមកបាដិហារ្យក្នុងថ្ងៃដែលប្រតិស្ឋានក្នុងព្រះចេតិយរួច ។

៥-ទ្រង់អធិដ្ឋានថា ព្រះសារីរិកធាតុរបស់អញតថាគតចំនួន ១ ទោណក្នុងលង្កាទ្វីបឯណោះ សូមកាន់យកនូវពុទ្ធភេទក្នុងពេលដែលប្រតិស្ឋានក្នុងមហាចេតិយរួច ហើយហោះទៅលើវេហាសានកាលយ៍ស្ដែងនូវយមកបាដិហារ្យកុំបីខាន ។

ព្រះរាជាលុះបានស្ដាប់ហើយ ទ្រង់មានព្រះហឫទ័យជ្រះថ្លាណាស់ ហើយក៏ទ្រង់ឲ្យចាត់ការធ្វើផ្លូវពីក្រុងបាដលិបុត្រយ៉ាងស្អាតរហូតដល់ព្រះមហាពោធិព្រឹក្ស ។

ឯព្រះវិស្សុកម្មទេវបុត្រ ក៏មកទទួលការធ្វើជាជាងសាងផើងមាសចំនួនកំពស់ ៥ ហត្ថ ទទឹង ៣ ហត្ថ កម្រាស់ ៨ អង្គុលី ។

ព្រះរាជាព្រមទាំងសេនាមាត្យ និងក្មេងត្បូងត្រី ព្រមទាំងអរិយសង្ឃច្រើនឥតគណនាបានយាង និមន្ត និងអញ្ជើញឆ្ពោះទៅកាន់ទីជិតព្រះ

មហាពោធិព្រឹក្ស ។

គេដើរប្រទក្សិណ ៣ ជុំ គេប្រគំតូរ្យតន្ត្រី គេថ្វាយគ្រឿងគន្ធពិដោរ គេដាក់ផើងមាសក្រោមទីនោះ រួចព្រះរាជាទ្រង់ឈរលើតេនបីឞ[11]យកដក់មាសគូសរាំសព្ទដ៏មែកមហាពោធិព្រឹក្សដោយមនោសិលាជាតិ រួចគេធ្វើសច្ចកិរិយាបួងសួងសូមអាកធនាមែកព្រះមហាពោធិព្រឹក្សខាងស្តាំ ទៅប្រតិស្ឋានដាច់ឯងធ្លាក់មកប្រតិស្ឋានលើផើងមាស ។

គេធ្វើបុណ្យអភិសេកក្នុងទីនោះ អស់ថ្ងៃ៧ ទើបគេជន្លែមកកាន់ក្រុងបាដលិបុត្រតំកល់ទុកនេះ ។ លុះព្រះសង្ឃមិត្តាថេរីត្រូវនិមន្តទៅលង្កាទ្វីប គេក៏ថ្វាយព្រះមហាពោធិព្រឹក្សនេះដល់ព្រះសង្ឃមិត្តាថេរីជន្លែទៅកាន់កំពង់សមុទ្រ អសោកក៏បានរៀនពិធីបូជានូវមហារាជសម្បត្តិក្នុងជម្ពូទ្វីបទាំងមូលដល់ព្រះមហាពោធិព្រឹក្សនេះ នាមាត់សមុទ្រនោះអស់ ៧ ថ្ងៃទៀត ។

គេឃើញអសោកចុះក្នុងទឹកសមុទ្រត្រឹមកទូលផើងព្រះមហាពោធិព្រឹក្សដាក់លើនាវា ។

គេឃើញព្រះសង្ឃមិត្តាថេរីព្រមទាំងភិក្ខុនីជាព្រះអរហន្តឯទៀតចំនួន ៥០០ អង្គ គង់លើនាវា ។

គេឃើញតែកម្រងផ្កាបុប្ផាផ្សេងៗ អណ្តែតដេរដាសពេញផ្ទៃសមុទ្រ ឥតមានព្យុះខ្យល់អ្វីទេ មានតែចលនាពួកនាគមកសូមការអនុញ្ញាតពីព្រះសង្ឃមិត្តាថេរីឲ្យផ្អាកដំណើរនេះចំនួន ៧ ថ្ងៃឲ្យពួកគេបានបូជាផងប៉ុណ្ណោះ ។

រួចនាវានេះបន្តដំណើរហូតដល់កំពង់ផែជម្ពុកោឡតែម្តង ។ រីឯក្នុងលង្កាទ្វីបឯណោះវិញ តាមបញ្ហាសុមនសាមណេរ និងដោយអានុភាពរបស់

---

(១១) អាសនៈសម្រាប់អង្គុយដែលធ្វើពីរតនៈ. ហៅថា តាំង ។

ព្រះមហិន្ទត្ថេរ និងព្រះរាជាផង ទីក្រុងទាំងមូលមានផង និងមហាប្រជាពុទ្ធសាសនិកមានសោកណាកាព និងអឹកធឹកច្រើនឥតគណនាឡើយ ដែលរង់ចាំទទួលនោះ ។

ក្នុងថ្ងៃ ១ កើត ខែ មិគសិរ គេឃើញព្រះទេវកន្យមួយតិស្សៈចុះក្នុងទឹកសមុទ្រត្រឹមក ចាំទទួលទូលព្រះមហាពោធិព្រឹក្សនោះ រួចគេរៀបអភិសេកនៅមាត់សមុទ្រនោះអស់ ៣ ថ្ងៃ ក្នុងថ្ងៃទី៤ ទើបគេដង្ហែទៅកាន់ក្រុងអនុរាធបុរី ។ គេដង្ហែព្រះមហាពោធិព្រឹក្សនេះតាមទ្វារខាងជើង កាត់ពាក់កណ្តាលក្រុងអនុរាធបុរី រចេញទៅទ្វារខាងត្បូង រួចចេញពីទិសខាងត្បូង, ព្រះពោធិព្រឹក្ស ព្រះពុទ្ធ ៣ អង្គស្ថិតនៅទីណា គេយកព្រះមហាពោធិព្រឹក្សនេះទៅប្រតិស្ឋានទុកក្នុងមហាមេឃវនុយ្យានទនាទីនោះក្នុងថ្ងៃពេញបូណ៌មី ខែ មិគសិរ ។

ជាការអស្ចារ្យណាស់ ព្រះមហាពោធិព្រឹក្សនេះ គ្រាន់តែដាក់ដាំផុតពីព្រះហស្តក្សាម ក៏ផុះឡើងមានកំពស់ ៨០ ហត្ថ ហើយអណ្តែតទៅលើមេឃ បញ្ចេញនូវឆព្វណ្ណរង្សី ៦ ពណ៌គ្របលង្កាទ្វីបទាំងមូលក៏ទល់ព្រហ្មលោកឯណោះ ។

ជា : មានបុរសចំនួន ១០.០០០ រូប ជ្រះថ្លានឹងមហាពោធិបាដិហារ្យនោះ តាំងខ្ជាប់នូវអនុបុព្វបែសស្សនាបួសសម្រេចព្រះអរហត្តទាំងអស់ ។ មហាមេឃស្រទំជាប់ ៧ ថ្ងៃ មានតែពន្លឺឆព្វណ្ណរង្សីប៉ុណ្ណោះ ។ ក្នុងថ្ងៃទី ៧ ព្រះមហាពោធិព្រឹក្សនេះ ក៏បញ្ចេញនូវដើម មែក ស្លឹក និងផ្លែ៤ ទៀតផង ។

គ្រានោះព្រះមហិន្ទត្ថេរ ព្រះសង្ឃមិត្តាថេរី ព្រះរាជាព្រមទាំងបរិវារ

និងពួកប្រជានិករជាច្រើនឥតគណនា ដែលនិមន្ត យាងនិងអញ្ជើញទៅកាន់ទីនោះ គេកំពុងតែទស្សនាដោយការអស្ចារ្យ ក៏ស្រាប់តែផ្លែមួយជ្រុះចាកមេឃធ្លាក់មកប្រតិស្ឋានក្នុងព្រះហស្ថព្រះមហាថេរៗលោកហុចទៅថ្វាយព្រះរាជាឲ្យយកទៅដាំៗភ្លាមក៏ដុះភ្លាម ហើយមានកូនចំនួន ៨ ដុះកំពស់ចំនួន ៤ ហត្ថ ភ្លាមដែរ ។

លុះប្រតិស្ឋានព្រះមហាពោធិព្រឹក្សរួចហើយ គេឃើញអនុឡាទេវីនិងរាជកញ្ញាព្រមទាំងកញ្ញាអ្នកបម្រើឯទៀតចំនួន ១.០០០ រូប បួសក្នុងសំ-ណាក់ព្រះសង្ឃមិត្តាថេរី មិនយូរប៉ុន្មានក៏បានលុះព្រះអរហត្តទាំងអស់ ។

ឯអរិដ្ឋអាមាត្យជាក្មួយស្តេច ព្រមទាំងបុរសចំនួន ៥០០ រូប ក៏បួសក្នុងសំណាក់ព្រះថេរៈ បានសម្រេចអរហត្តទាំងអស់ដែរ ។

ក្រែងមានការវិវត្តន៍នៃពុទ្ធសាសនានាអនាគត នោះទើបមហិន្ទត្ថេរនិងស្តេចបញ្ជាឲ្យឆ្លាក់សិលាចារឹកទុកក្បែរថូបារាមចេតិយនោះថា សូមឲ្យព្រះនត្តានាមទុដ្ឋគាមណីអភ័យជាចៅស្តេចទេវានម្បិយតិស្សៈ ដែលនឹងសោយរាជ្យក្នុងលង្កា នាអនាគតនោះកសាងថែមទូវព្រះស្តូបក្នុងប្រទេសនេះទៀតផង ។

ដោយវត្ថុបំណងឲ្យឫសពុទ្ធសាសនាដុះជាប់ក្នុងលង្កានេះ ទើបព្រះរាជាចាត់ឲ្យសាងមណ្ឌបត្រង់បរិវេណរបស់មេឃវណ្ណាភយរាជ ដើម្បីសង្គា-យនាវិន័យ និងធម៌នាវត្តថូបារាមនោះ ។

ឯការកសង្ឃសន្និបាតចំនួន ៦៨.០០០ រូប មានព្រះមហិន្ទត្ថេរជាប្រធាន មហាអរិដ្ឋត្ថេរអ្នកសម្តែងវិន័យ, ព្រះចៅទេវានម្បិយតិស្សៈអ្នក

ឧបត្ថម្ភក៏ ប្រារព្ធការប្រតិស្ឋាន[១២] ពុទ្ធសាសនាក្នុងទ្វីបនេះ ធ្វើក្នុងវត្តថូបារាម ក្រុងអនុរាធបុរី (ចាប់ធ្វើក្នុងព.ស. ២៣៨ មហិន្ទត្ថេរបួសបាន ១៤ វស្សា ហើយ ១០ ខែ ទើបចប់) ។

## ៤-ការចារឹកពុទ្ធវចនៈជាតួអក្សរ

មែនពិតក្នុងមហាសន្និបាតនៃមហាសង្គីតិកាល និងអនុសង្គីតិកាល ទាំង៣ លើកក្នុងជម្ពូទ្វីប ហើយមួយលើកទៀតក្នុងលង្កាទ្វីបនេះ, គ្រាន់តែសង្គាយនាហើយសូត្រតម្រឹមគ្នាជារបៀបមួយដោយមាត់ទទេប៉ុណ្ណោះ មិនទាន់បានចារឹកពុទ្ធវចនៈនោះជាតួអក្សរនៅឡើយទេ ។

លុះមកដល់ព.ស. ៤៤៣ ឆ្នាំ គឺក្នុងរជ្ជកាលនៃព្រះបាទវដ្តគាមណី-

---

(១២) ថា : ១២ ឆ្នាំ អំពីការប្រតិស្ឋានពុទ្ធសាសនាជាដំបូងក្នុងលង្កានេះទៅ ព្រះនាងអសន្ធិមិត្តាទ្រង់វិលាល័យ។ ថា : ៤ ឆ្នាំ អំពីការសោយវិលាល័យនៃព្រះនាងអសន្ធិមិត្តានោះមក ទើបអសោកយកនាងតិស្សរក្សាទៅជាអគ្គមហេសីថ្មីទៀត។ ថា : ក្នុងឆ្នាំទី ៣ អំពីនោះមកស្ត្រីទុយិសនេះ បានឱ្យគេយកឆ្អឹងបំពែលទៅចាក់សម្លាប់មហាពោធិព្រឹក្ស។ (ថា : ស្ត្រីអបលក្ខណ៍នេះ បានលួចស្រឡាញ់កុណាលកុមារជាបុត្រព្រះនាងអសន្ធិមិត្តា តែកុមារនេះមិនព្រម. ថា : ស្ត្រីពាលនេះញុះញង់អសោកឱ្យនិរទេសកុណាល និងអគ្គជាយានាម កាញ្ចនមាលាទៅវង្គតក្ខារ. ថា : ស្ត្រីបរិយនេះ បានសរសេរសំបុត្រក្លែងក្លាយឱ្យគេឆ្កៀលភ្នែកកុណាលទាំងពីរ. ថា : អគ្គជាយារបស់កុណាលបានដឹកដៃស្វាមីខ្វាក់ប្លែងភេទជាអ្នកច្រៀងចូលមកក្រុងបាដលិបុត្រ. ថា : អសោកបានឮ និងឃើញកុណាលក៏ហៅមកសួរ. ថា : អសោកជ្រាបនូវព្រឹត្តិការណ៍ដ៏គគ្រក់នេះ ក៏បញ្ជាឱ្យគេដុតនាងតិស្សរក្សាទាំងរស់ ឯអ្នក ផ្សេងទៀតនិរទេស. ថា : ជាការអស្ចារ្យណាស់ កុណាលកុមារមានព្រះនេត្រជាដូចដើមវិញ) ។ ថា : អសោកសោយរាជ្យបាន ៣៧ ឆ្នាំ ទើបសុគត. ថា : អសោកមានក្តីក្រេវក្រោធនឹងសេវកាមាត្យ ដែលគេមិនព្រមចំណាយរាជទ្រព្យឱ្យទានក្នុងពេលជិតសុគតៗទៅធ្លាក់ទៅទុគ្គតិដែរ ។

ថា : ស្តេចទេវានម្បិយតិស្សៈសោយរាជ្យបាន ៤០ ឆ្នាំ ទើបចូលទិវង្គត. ថា : អ្នកស្រុកលង្កាបានទុកព្រះមហិន្ទត្ថេរជាដូងព្រះអាទិត្យ ទុកព្រះសង្ឃមិត្តាថេរីជាដូងព្រះច័ន្ទ។ ថា : ព្រះមហិន្ទត្ថេរមានព្រះជន្មាយុ ៦០ ឆ្នាំ ទើបបរិនិព្វាន (សារត្ថទីបនីថា : ៦២) ។ ថា : ព្រះសង្ឃមិត្តាថេរីមានព្រះជន្មាយុ ៥៩ ឆ្នាំ ទើបបរិនិព្វាន. ទាំងពីរអង្គបងប្អូននេះបរិនិព្វានក្នុងលង្កាទ្វីប ។ ថា : គេសាងព្រះស្តូបពីរដ៏វិចិត្រក្នុងមហាមេឃវនុយ្យាន សម្រាប់បញ្ចុះព្រះធាតុព្រះអង្គទាំងពីរនេះទុកជាទីសក្ការបូជា ។

អភ័យកសាងវត្តអភយគិរីរួចនោះ, ទើបព្រះអរិយសង្ឃទាំងឡាយចំនួន ១.០០០ រូប មានព្រះពុទ្ធត្តជាប្រធាន មានទស្សនៈថា ការចេះចាំនូវពុទ្ធវចនៈមាត់ទទេនោះ មានភាពទន់ខ្សោយជាលំដាប់, ដូច្នេះព្រះអរហន្តទាំងនោះក៏សរសេរនូវព្រះត្រៃបិដក ព្រមទាំងអដ្ឋកថា និងថេរវាទជាសីហលភាសាចុះទុកក្នុងគម្ពីរស្លឹករឹតជាសក្ខីភាពមក, ប្រជុំធ្វើក្នុងវត្តអភយគិរីមលយជនបទលង្កាទ្វីប ដោយមានព្រះបាទវដ្តគាមណីអភ័យជាអ្នកឧបត្ថម្ភក៏១ឆ្នាំទើបចប់។

## ៥-អ្នកចម្លងគម្ពីរពីលង្កាមកវិញ

លុះ ព.ស ៩៥៦ ឆ្នាំ ក្នុងរជ្ជកាលព្រះបាទមហានាម នាលង្កាទ្វីបនេះ ។

ឯក្នុងជម្ពូទ្វីបជិតពោធគយា មានមាណពម្នាក់ឈ្មោះ ឃោសកុមារជាកូនព្រាហ្មណ៍ កុមារនេះចេះចប់នូវត្រៃវេទទាំង ៣ ផង ។

កុមារតែងដើរសួរបញ្ហាផ្សេងៗ តែគ្មានមនុស្សណាឆ្លើយរួចឡើយ។ លុះទៅដល់វត្តមួយ មានភិក្ខុចំនួនជាង ១០០ រូប មានព្រះអរហន្តនាមរេវតត្ថេរជាប្រធាន មាណពនោះក៏ចូលទៅសួរបញ្ហា ព្រះអរហន្តអង្គនេះឆ្លើយរួចទាំងអស់, រួចលោកថា : មាណពឯងសួរអាត្មាច្រើនណាស់ហើយ ឥឡូវនេះអាត្មាសូមសួរម្តងវិញ ។

ព្រះថេរៈសួរក្នុងចិត្តយមកៈ មាណពនោះឥតឆ្លើយរួចឡើយ, ទើបសុំបួស លុះព្រះថេរៈបំបួសរួច ភិក្ខុថ្មីនេះក៏បានរៀននូវព្រះត្រៃបិដកអំពីសំណាក់គ្រូ ចេះចាំរត់មាត់ទទេ ហើយបាននាមថា ពុទ្ធឃោសភិក្ខុផង ។

ពុទ្ធឃោសភិក្ខុកាលនៅវត្តនោះ ប្រុងប្រឹងធ្វើគម្ពីរញាណោទ័យ ព្រមទាំងគម្ពីរអដ្ឋសាលិនី និងអដ្ឋកថាបរិត្តផង ។

ព្រះរេវតត្ថេរជាគ្រូមានថេរដីកាថា ម្នាលពុទ្ធឃោសភិក្ខុ ! ក្នុងជម្ពូទ្វីបនេះ ព្រះពុទ្ធវចនៈមានតែបាលីសុទ្ធ ឯអដ្ឋកថា និងថេរវាទមិនមានទេ មានដែរតែជាសីហលភាសា ហើយនៅឯសីហលទ្វីបឯណោះផង ដូចនេះ ចូរលោកទៅសីហលទ្វីបពិនិត្យមើលឲ្យសព្វគ្រប់ហើយ ប្រែ និងចម្លងមកជាមគធភាសាវិញ ទើបសម្រេចប្រយោជន៍ដល់មនុស្សលោកទាំងអស់បាន ។

លុះឮហើយ ក៏មានសេចក្តីរីករាយណាស់ ទើបថ្វាយបង្គំលាគ្រូ និងព្រះសង្ឃទៅកំពង់សមុទ្រឡើងនាវាទៅភ្លាម ដល់កណ្តាលសមុទ្របានជួបនិងព្រះពុទ្ធទត្តត្ថេរដែរ, បានសន្ទនាគ្នារួចហើយ ក៏បន្តដំណើរទៅលង្កាទ្វីបតែម្តង ។

ពុទ្ធឃោសភិក្ខុបានទៅជួបព្រះសង្ឃក្នុងមហាវិហារ ទើបហួសទៅជួបព្រះសង្ឃបាលត្ថេរក្នុងមហាបធានឃរៈទៀត, ហើយបានទៅស្តាប់នូវអដ្ឋកថាជាសីហលភាសា និងថេរវាទទៀតផង ។

ដោយពុទ្ធឃោសភិក្ខុបានឃើញនូវបាលីព្រះត្រៃបិដក និងអដ្ឋកថានោះ ក៏ចាប់ប្រែបានជាគម្ពីរវិសុទ្ធិមគ្គមុនមួយភ្លាម ។ រួចយកទៅបង្ហាញព្រះសង្ឃៗឃើញនូវសមត្ថភាពដ៏អស្ចារ្យបែបនេះ ក៏ប្រគល់នូវបាលីព្រះត្រៃបិដក និងអដ្ឋកថាជាសីហលភាសានោះឲ្យមកទាំងអស់, ពុទ្ធឃោសភិក្ខុយកគម្ពីរទាំងនេះទៅធ្វើ និងប្រែក្នុងប្រាសាទមួយឈ្មោះបធានឃរៈ នាភាគទក្សិណនៃមហាវិហារ ។

តាមពត៌មាននេះថា : អដ្ឋកថាដែលព្រះសង្ឃលង្កាទ្វីបបានរចនាហើយនោះមាន ៣ បែបគឺ :

១-អដ្ឋកថាដែលឡើងកាន់មហាសង្គាយនា ហើយដែលព្រះមហិន្ទ-ត្ថេរត្រាធការធ្វើជាសីហលភាសានោះហៅថា មហាអដ្ឋកថា ។

២-អដ្ឋកថាដែលព្រះសង្ឃលង្កាប្រជុំគ្នាធ្វើលើក្បូនថ្មដែនោះហៅថា បច្ចរិយដ្ឋកថា ។

៣-អដ្ឋកថាដែលព្រះសង្ឃលង្កាប្រជុំគ្នាធ្វើក្នុងកុរុន្ទិវេឡុវិហារនោះហៅថា កុរុន្ទដ្ឋកថា ។

ឯភេទៈដែលព្រះថេរៈចាស់ទុំជាន់មុនទាំងឡាយ បានរចនាតាមលំនាំបាលីនោះហៅថា ថេរភេទ ។

ពុទ្ធឃោសភិក្ខុបានប្រែចម្លងនូវកុរុន្ទដ្ឋកថា ពីសីហលភាសាមកជាមគធភាសាវិញនោះ ធ្វើជាអដ្ឋកថាវិន័យ ។

ប្រែចម្លងនូវមហាអដ្ឋកថា ពីសីហលភាសាមកជាមគធភាសាវិញនោះ រចនាធ្វើជាអដ្ឋកថាព្រះសូត្រ ។

ហើយប្រែចម្លងនូវបច្ចរិយដ្ឋកថា ពីសីហលភាសាមកជាមគធភា-សាវិញនោះ រចនាធ្វើជាអដ្ឋកថាអភិធម្ម ។

ការប្រែចម្លងនេះ ១ ឆ្នាំ ទើបចប់ ។ រួចហើយក៏ថ្វាយបង្គំលាព្រះសង្ឃត្រឡប់មកជម្ពូទ្វីបវិញហោង ។

## ៦-អ្នកចម្លងគម្ពីរនេះបន្តមកទៀត

លុះដល់មក ព.ស. ១៤៦០ ព្រះចៅធម្មានុរុទ្ធ ប្រទេសភូមា ក្រុងអរិមទ្ទបុរៈ ព្រមទាំងបព្វជិត និងគ្រហស្ថជាបណ្ឌិតជាច្រើនទ្រង់យាង និមន្តតាមសំពៅពីរទៅគាល់ និងថ្វាយព្រះពរព្រះចៅលង្កានាម លង្កិស្សរាជ និងថ្វាយបង្គំព្រះសង្ឃលង្កា នាវត្តមេឃគិរីមហាវិហារផង, រួចសុំចម្លងព្រះ

ត្រៃបិដកជាភាសាបាលី និងជាសីហលភាសាផង សុំទាំងព្រះកែវមរកតដាក់នាវាវិលមកស្រុកវិញ ។

លុះដល់កណ្ដាលសមុទ្រ នាវាដែលដាក់ព្រះត្រៃបិដកជាភាសាបាលី និងព្រះភជាគង់នោះ ក៏ត្រូវខ្យល់ព្យុះបក់សោត់មកជាប់ទីនីត្រើយសមុទ្រភូមា, ឯនាវាដែលដាក់ព្រះកែវមរកត និងព្រះត្រៃបិដកជាសីហលភាសានោះ សោត់មកជាប់ទីនីត្រើយសមុទ្រកម្ពុជរដ្ឋ ។

គេចាប់យកវត្ថុទាំងនោះទៅថ្វាយព្រះចៅកម្ពុជានាម សុរ្យវរ្ម័នទី១ ក្រុងស្រីយសោធរបុរៈ ។ ក្រោយមកព្រះចៅភូមាទ្រង់ផ្ញើព្រះរាជសារមកសុំយកវត្ថុនេះវិញ ស្ដេចកម្ពុជាថ្វាយតែព្រះត្រៃបិដក ឯព្រះកែវ[13]មរកត ទ្រង់សុំទុក ។

---

(១៣) ថា : នាគសេនត្ថេរជាព្រះអរហន្ដមានបំណងកសាងព្រះពុទ្ធបដិមា. ជ្រាបដល់ព្រះឥន្ទ្រក៏បញ្ជាវិស្សកម្មទេវបុត្រឱ្យទៅយកកែវមណីជោតិនៅភ្នំវេបុល្ល ។ កុម្ភណ្ឌថា : កែវនេះថ្វាយពុំបានទេ ព្រោះគេទុកសម្រាប់ស្ដេចចក្រពត្តិ តែមានកែវមរកតនៅបាទភ្នំវេបុល្លជាកែវឥតម្ចាស់ ។ តមកព្រះឥន្ទ្រ និងវិស្សកម្មទេវបុត្រទៅបញ្ជាឱ្យកុម្ភណ្ឌយកកែវនោះមកឱ្យ បានហើយក៏យកមកប្រគេនព្រះនាគសេនត្ថេរ ។ ដោយរតនជាតិគឺកែវមរកតដែលមានពណ៌ដូចត្រួយចេកនោះរឹងពេក ព្រះឥន្ទ្រក៏បញ្ជាឱ្យវិស្សកម្មទេវបុត្រកសាងប្រគេន ។ ព្រះពុទ្ធរូបកែវមរកតនេះ កសាងក្នុងព.ស. ៥០០ មានកំពស់ ១ ហត្ថ ៧ ធ្នាប់ និងព្រះភ្លែន ២៣ ធ្នាប់ ។ រួចលោកបញ្ចុះទូវមហាបុរិសលក្ខណៈចំនួន ៧ អង្គ ក្នុងព្រះពុទ្ធបដិមានោះគឺ ព្រះសិរៈ (ឆ្អឹងក្បាល) ១. ព្រះនលាដៈ (ឆ្អឹងថ្ងាស) ១. ព្រះឧរៈ (ឆ្អឹងទ្រូង) ១. ព្រះអង្សា (ឆ្អឹងស្មាស្ដាំ-ឆ្វេងទាំងពីរខាង) ១. ព្រះជង្សា (ឆ្អឹងស្មងស្ដាំ-ឆ្វេងទាំងពីរខាង) ១ ។ រួចដោយមានព្រះនាគសេនត្ថេរជាប្រធាន គេធ្វើបុណ្យសម្ពោធអភិសេកព្រះពុទ្ធបដិមានេះក្នុងវត្តអសោការាម ក្រុងបាដលិបុត្រ រដ្ឋមគធៈអឹកធឹកណាស់ ។ លុះក្នុងព.ស. ១.០០០ នារជ្ជកាលស្ដេចសិរិកិត្តិរាជ រដ្ឋមគធៈកើតសឹកសង្គ្រាម ពុទ្ធសាសនាក៏ចេះតែថយចុះ គេក៏និមន្តព្រះកែវមរកតនេះទៅប្រតិស្ឋានក្នុងវត្តមេឃគិរីមហាវិហារនោលង្កាទ្វីប ។ លុះព.ស.១៥៦០ ព្រះបាទធម្មានុរុទ្ធស្ដេចភូមាទៅចម្លងគម្ពីរពីលង្កា សុំព្រះពុទ្ធរូបកែវមរកតនេះដាក់សំពៅមកជាបុព្វលាភព្រះពុទ្ធរូបអង្គនេះ ក៏ទ្រង់គង់សំពៅនិមន្តចូលមករដ្ឋកម្ពុជាវិញ ។

(នេះសឲ្យឃើញថា : ព្រះត្រៃបិដក និងអដ្ឋកថាដែលចារឹកជាតួអក្សរ ផ្សាយចូលមកក្នុងជ្រោយសុវណ្ណភូមិ គឺ ភូមា និងកម្ពុជា ក្នុងសម័យនោះឯង) ។

( ប្រវត្តិពុទ្ធសាសនាចប់ )

## ប្រវត្តិរបស់ព្រះពុទ្ធ៤អង្គនាភទ្ទកប្បនេះ (បន្ថែម)

១-គោត្រ : ព្រះកកុសន្ធោ ព្រះកោនាគមនោ ព្រះកស្សបោ ទាំង ៣ អង្គនេះជាកស្សបគោត្រ ឯព្រះសមណគោតមជាគោតមគោត្រ ។

២-ជាតិ : ព្រះកកុសន្ធោ ព្រះកោនាគមនោ ព្រះកស្សបោ ទាំង ៣ អង្គនេះជាជាតិព្រាហ្មណ៍ ឯព្រះសមណគោតមជាខត្តិយជាតិ ។

៣-ចេញទ្រង់ព្រះផ្នួស : ព្រះកកុសន្ធោ គង់រថទឹមសេះអាជានេយ្យ ព្រះកោនាគមនោគង់ដំរី ព្រះកស្សបោគង់ប្រាសាទ[១៤] ឯព្រះសមណគោតមគង់កណ្ឋកៈអាជានេយ្យ ។

៤-ធ្វើទុក្ករកម្ម : ព្រះកកុសន្ធោ ១០ ខែ ព្រះកោនាគមនោ ៦ ខែ ព្រះកស្សបោចំនួន ៧ ថ្ងៃ ឯព្រះសមណគោតមចំនួន ៦ ឆ្នាំ ។

៥-សាវកសន្និបាត : ព្រះកកុសន្ធោ មានសាវកសន្និបាតតែម្តងមានអរហន្ត-ភិក្ខុចំនួន ៤០.០០០ អង្គ មករួមសន្និបាត រីព្រះកោនាគមនោ មានសាវក-សន្និបាតមួយដងដែរ មានអរហន្តភិក្ខុចំនួន ៣០.០០០ អង្គ មករួមសន្និបាត ឯព្រះកស្សបោ ក៏មានសាវកសន្និបាតមួយដងដែរ និងមានអរហន្តភិក្ខុចំនួន ២០.០០០ អង្គ មករួមសន្និបាត ឯព្រះសមណគោតម ក៏មានសាវកមួយដងដែរ ហើយមានអរហន្តភិក្ខុចំនួន ១.២៥០ អង្គ មករួមសន្និបាត ។

៦-គូនៃអគ្គសាវក : ព្រះកកុសន្ធោមានវិធុរៈអរហន្តជាអគ្គសាវកទី១ និងសញ្ជីវៈអរហន្តអគ្គសាវកទី២ រីព្រះកោនាគមនោមានភិយ្យោសៈអរហន្តជាអគ្គសាវកទី១ និងឧត្តរៈអរហន្តជាអគ្គសាវកទី២ រីព្រះកស្សបោមានតិស្សៈ-

(១៤) ព្រះកស្សបោគង់ប្រាសាទដោយអណ្តែតទាំងតួប្រាសាទទៅតែម្តង ។

អរហន្តជាអគ្គសាវកទី១ និងភិក្ខុឈ្មោះអរហន្តជាអគ្គសាវកទី២ ឯព្រះសមណគោតមមានព្រះសារីបុត្តត្ថេរជាអគ្គសាវកទី១ និងព្រះមោគ្គល្លានត្ថេរជាអគ្គសាវកទី២ ។

**៧-ឧបដ្ឋាកភិក្ខុ** : ព្រះកកុសន្ធោមានវុឌ្ឍិជភិក្ខុជាពុទ្ធុបដ្ឋាក ព្រះកោនាគមនោមានសោត្ថិជភិក្ខុជាពុទ្ធុបដ្ឋាក ព្រះកស្សបោមានសព្វមិត្តភិក្ខុជាពុទ្ធុបដ្ឋាក ឯព្រះសមណគោតមមានអានន្ទត្ថេរជាពុទ្ធុបដ្ឋាក ។

**៨-ព្រះជន្មាយុ** : ព្រះកកុសន្ធោ ៤០.០០០ ឆ្នាំ ព្រះកោនាគមនោ ៣០.០០០ ឆ្នាំ ព្រះកស្សបោ ២០.០០០ ឆ្នាំ ឯព្រះសមណគោតម ៨០ ឆ្នាំគត់ ។

**៩-ព្រះមាតាបិតា** : អគ្គិទត្តព្រាហ្មណ៍ និងនាងវិសាខាព្រាហ្មណីជាព្រះមាតាបិតារបស់ព្រះកកុសន្ធោ ក្នុងនគរខេមវតី ព្រះរាជានាម ខេមកជ, យញ្ញទត្តព្រាហ្មណ៍ និងនាងឧត្តរព្រាហ្មណីជាព្រះមាតាបិតារបស់ព្រះកោនាគមនោ ក្នុងនគរសោភៈ ស្តេចនាម សោភកជ, ព្រហ្មទត្តព្រាហ្មណ៍ និងនាងធនវតីព្រាហ្មណីជាព្រះមាតាបិតារបស់ព្រះកស្សបោ ក្នុងនគរពារាណសី ព្រះរាជានាម កិកីរាជ, សុទ្ធោទនមហារាជ និងព្រះរាជទេវីនាម សិរិមហាមាយា ជាព្រះមាតាបិតារបស់ព្រះសមណគោតម ក្នុងនគរកបិលពស្តុ ។

**១០-ព្រះពោធិព្រឹក្ស** : ដើមច្រេសជាមហាពោធិព្រឹក្សរបស់ព្រះកកុសន្ធោ ដើមល្វាជាមហាពោធិព្រឹក្សរបស់ព្រះកោនាគមនោ ដើមជ្រៃជាមហាពោធិព្រឹក្សរបស់ព្រះកស្សបោ ដើមអស្សត្ថព្រឹក្សជាមហាពោធិព្រឹក្សរបស់ព្រះសមណគោតម ។

**១១-អធិការ** : ព្រះកកុសន្ធោ ព្រះកោនាគមនោ ព្រះកស្សបោ ជាសទ្ធាធិក, ឯព្រះសមណគោតមជាបញ្ញាធិក ។

**១២-ពុទ្ធជាយា "កន្សែសារពេជ្ជ" :** អប្បរោជិនីជាព្រះជាយាព្រះកកុសន្ធោ និងបុត្រមួយឈ្មោះ អនុត្តរៈ, សុភាវតីជាជាយាព្រះកោនាគមនោ និងបុត្រមួយឈ្មោះ សត្ថវាហៈ, សុនន្ទាជាជាយាព្រះកស្សបោ និងបុត្រមួយឈ្មោះ វិជិតសេនា, ព្រះរាជកញ្ញានាម យសោធរា[illegible]ជាអគ្គមហេសីរបស់ព្រះសិទ្ធត្ថ មានរាជបុត្រមួយនាម រាហុល ។

**១៣-បល្ល័ង្ក កំពស់ និងរស្មី :** ព្រះកកុសន្ធោមានព្រះបល្ល័ង្កកំពស់ ២៦ ហត្ថ កំពស់ព្រះអង្គ ៤០ ហត្ថ មានព្រះរស្មីផ្សាយចេញរាប់មិនបាន, ព្រះកោនា-គមនោមានព្រះបល្ល័ង្កកំពស់ ២០ ហត្ថ កំពស់ព្រះអង្គ ៣០ ហត្ថ មានព្រះរស្មីផ្សាយចេញរាប់មិនបាន, ព្រះកស្សបោមានព្រះបល្ល័ង្ក ១៥ ហត្ថ កំពស់ព្រះអង្គ ២០ ហត្ថ មានព្រះរស្មីផ្សាយចេញរាប់មិនបាន, ព្រះសមណគោតម មានព្រះបល្ល័ង្ក ១៤ ហត្ថ កំពស់ព្រះអង្គ ១៨ ហត្ថ មានព្រះរស្មីផ្សាយចេញ ១ ព្យាមជុំវិញទាំងពីរខាង ។

ដោយឡែកអនាគត ទីងមានព្រះសិអារ្យមេត្រីត្រាស់នាភទ្ទកប្បនេះដែរ មានព្រះជន្ម ៨០.០០០ ឆ្នាំ ដើមទ្រីងជាពោធិព្រឹក្ស រតនបល្ល័ង្ក ៥៣ ហត្ថ កំពស់ព្រះអង្គ ៨០ ហត្ថ ទុក្ករកម្ម ៧ ថ្ងៃ គង់ប្រាសាទ(១៥)ចេញបួស មានព្រះរស្មីផ្សាយចេញរាប់មិនបាន ព្រះអង្គជាព្រាហ្មណជាតិ ព្រះបិតានាម សុព្រហ្មាព្រាហ្មណ៍ ព្រះមាតានាម ព្រហ្មវតីព្រាហ្មណី អគ្គមហេសីនាម ចន្ទមុខី បុត្រនាម ព្រហ្មវឌ្ឍន៍ នគរឈ្មោះ កេតុមតី, ព្រះបាទកេតុមារាជ, ព្រះជាវីរិយាធិក ។

( ចាកអាគតដ្ឋាននានាភាគច្រើនមហាបទានសុត្តវណ្ណនា )

---

(១៥) ព្រះសិអារ្យមេត្រីគង់ប្រាសាទអណ្តែតទាំងតួទៅដូចព្រះកស្សបោដែរ ។

# បកិណ្ណកកថា

អនិសម្ម កតំ កម្មំ
អនវត្ថាយ ចិន្តិតំ
ភេសជ្ជស្សេវ វេបន្នា
វិបាកោ ហោតិ បាបកោ ។
និសម្ម ច កតំ កម្មំ
សម្មាវត្ថាយ ចិន្តិតំ
ភេសជ្ជស្សេវ សម្បត្តិ
វិបាកោ ហោតិ ភទ្ទកោ ។

កិច្ចការណាដែលមិនបានពិចារណាហើយធ្វើ, ទិនដែលមិនបានប្រៀបធៀបថ្លឹងគិតឲ្យសព្វគ្រប់ជុំវិញសិនទេ, នោះគេគង់នឹងទទួលផលអាក្រក់មិនខាន ដូចគុណវិបត្តិនៃថ្នាំពេទ្យ ។

បើកិច្ចការណាដែលគេបានពិចារណាហើយសឹមធ្វើ, ទិនដែលបានប្រៀបធៀបថ្លឹងគិតត្រឹមត្រូវជាក់លាក់ហើយ នោះគេរមែងបានទទួលនូវផលល្អជាដាច់ខាត ដូចគុណសម្បត្តិនៃថ្នាំពេទ្យ ។

អលសោ គិហិ កាមភោគី ន សាធុ,
អសញ្ញតោ បព្វជិតោ ន សាធុ,
រាជា ន សាធុ អនិសម្មការី,
យោ បណ្ឌិតោ កោធនោ តំ ន សាធុ ។

*គ្រហស្ថអ្នកបម្រើកាមខ្ជិលច្រអូសមិនល្អទេ,*
*អ្នកបួសមិនសង្រួមកាយ វាចា ចិត្តមិនល្អទេ,*
*ស្តេចឬឥស្សរជនមិនមានការពិចារណាមិនល្អទេ,*
*បណ្ឌិតណាអ្នកក្រេវក្រោធ នោះមិនល្អទេ ។*

*( សោមនស្សជាតកវីសតិនិបាត )*

ន សោ  រាជា យោ អជេយ្យំ ជិនាតិ,
ន សោ សខា យោ សខារំ ជិនាតិ,
ន សា ភរិយា យា បតិនោ ន វិភេតិ,
ន តេ បុត្តា យេ ន ភរន្តិ ជិណ្ណំ ។

*ជនណាឈ្នះមាតាបិតា ជននោះមិនឈ្មោះថា ស្តេចទេ,*
*មិត្រសំឡាញ់ណាឈ្នះមិត្រសំឡាញ់ នោះមិនឈ្មោះថា មិត្រទេ,*
*បុរសស្ត្រីណាមិនគោរពខ្លាចចិត្តប្ដីប្រពន្ធ នោះមិនឈ្មោះថាភរិយាស្វាមីទេ,*
*បុត្រធីតាណាមិនចិញ្ចឹមមាតាបិតាចាស់ នោះមិនឈ្មោះថា បុត្រធីតាទេ ។*

ន សា សភា យត្ថ ន សន្តិ សន្តោ,
ន តេ សន្តោ យេ ន ភណន្តិ ធម្មំ,
រាគញ្ច ទោសញ្ច បហាយ មោហំ,
ធម្មំ ភណន្តាយេវ ភវន្តិ សន្តោ ។

សប្បុរសជនមិនមានក្នុងសភាណា ទីប្រជុំនោះមិនឈ្មោះថា សភា ទេ, ជនណាមិនពោលធម៌ ជននោះមិនឈ្មោះថា សប្បុរសទេ, លុះតែលះបង់រាគៈ ទោសៈ និងមោហៈ ហើយមានតែធម៌សុទ្ធ ទើបឈ្មោះថា សប្បុរស ។

( មហាសុតសោមជាតកអសីតិនិបាត )

សុទុល្លភិត្ថី បុរិសស្ស យា ហិតា,
ភត្តិត្ថិយា ទុល្លភោ យោ ហិតោ ច ។

ស្ត្រីជាភរិយាណាប្រព្រឹត្តល្អដល់បុរស ស្ត្រីនោះគេមិនងាយរកបាន ទេ, បុរសជាប្តីណាប្រព្រឹត្តល្អដល់ស្ត្រី បុរសនោះក៏គេមិនងាយរកបានដែរ ។

( សម្ពុលាជាតកតិំសតិនិបាត )

ទុល្លភោ ហិ មនុស្សត្តំ,
សទ្ធា ច បន ទុល្លភា,
ទុល្លភោ ជិនស្ស ធម្មោ,
ទេសកោ ចាបិ ទុល្លភោ ។

ភាពដែលកើតជាមនុស្ស គេរកបានក្រណាស់,
ការជឿសមហេតុ-ផល ក៏រកបានក្រណាស់ដែរ,
ធម៌របស់អ្នកឈ្នះកិលេសតណ្ហា គេមិនងាយបានជួបទេ,
អ្នកចង្អុលធម៌ពិត ក៏មិនងាយជួបប្រទះដែរ ។

( មហាវង្ស )

នគ្គា នទី អនោទកា, នគ្គំ រដ្ឋំ អរាជិកំ
ឥត្ថីបិ វិធវា នគ្គា យស្សាបិ ទស ភាតរោ ។

ស្ទឹងមិនមានទឹកឈ្មោះថា ស្ទឹងអាក្រាត,
រដ្ឋមិនមានអ្នកកាន់ការឈ្មោះថា រដ្ឋអាក្រាត,
ស្ត្រីណាមានបងប្អូនសម្បី ១០ នាក់ តែមិនមានប្ដីឬទៅព្រៅ ស្ត្រីនោះ
ឈ្មោះថា អាក្រាត ។

( ខុទ្ទកនិកាយជាតកឯកនិបាត )

**គោណំ ធេនុញ្ច យានញ្ច**
**ភរិយំ ញាតិកុលេ ន វាសយេ ។**

*(ទ្រព្យទាំង៤ គឺ :) គោពេញប្រើ១, មេគោមានទឹកដោះ១, រទេះយានល្អ១, ភរិយាមានរូប១, មិនត្រូវឲ្យនៅឆ្ងាយពីខ្លួនឬឲ្យនៅឆ្ងាយពីក្នុងត្រកូលញាតិខ្លួនទេ ។*

*( កុណាលជាតកអសីតិនិបាត )*

**យស្ស រុក្ខស្ស ឆាយាយ,**
**និសីទេយ្យ សយេយ្យ វា,**
**ន តស្ស សាខំ ភញ្ជេយ្យ,**
**មិត្តទុព្ភោ ហិ បាបកោ ។**

*មនុស្សយើងបើដេកក្រោមម្លប់ឈើណា,*
*មិនត្រូវកាច់មែកឈើនោះចោលទេ,*
*ព្រោះវាក្លាយជាមនុស្សទ្រុស្តមិត្រដ៏អាក្រក់ ។*

*( មហាពោធិជាតកបញ្ញាសនិបាត )*

**យស្សេតេ ចតុរោ ធម្មា វានរិន្ទ យថា តវ**
**សច្ចំ ធម្មោ ធិតិ ចាគោ ទិដ្ឋំ សោ អតិវត្តតិ ។**

ម្នាលស្តេចវានរ ! ជនណាមានគុណធម៌ទាំង ៤ នេះគឺ វចីសច្ចៈ (ពាក្យពិត)១, ធម្មៈ (វិចារណញ្ញាណ)១, ធិតិ (ព្យាយាមមិនបន្ថយ)១, ចាគៈ (តស៊ូសុខចិត្តលះជីវិត)១, ជននោះរមែងកន្លងផុតនូវគ្រោះថ្នាក់ដូចអ្នកមិនខាន ។

( វានរិន្ទជាតកឯកនិបាត )

**អារោគ្យមិច្ឆេ បរមញ្ច លាភំ**
**សីលញ្ច ពុទ្ធានុមតំ សុតញ្ច**
**ធម្មានុវត្តី ច អលីនតា ច**
**អត្ថស្ស ទ្វារា បមុខា ឆឡេតេតិ ។**

មនុស្សត្រូវប្រាថ្នានូវបរមលាភគឺភាពដែលមិនមានរោគ១, នូវអាចារសីលឬលោកចារិត្តសីល១, នូវឱវាទរបស់បណ្ឌិត១, នូវការស្តាប់ឲ្យបានច្រើន១, នូវការអនុវត្តតាមសុចរិតធម៌១, នូវភាពនៃចិត្តក្លាហានមិនរួញរា១, គុណធម៌ទាំង ៦ នេះ ជាប្រមុខឬជាទ្វារសម្រាប់ហូរចូលមកនៃប្រយោជន៍ (ទាំង៣) ។

( អត្ថស្សទ្វារជាតកឯកនិបាត )

កាលពុទ្ធសាសនាមិនទាន់កើតនោះ ភូមិភាគនៃមជ្ឈិមប្រទេស មានរបៀបរបបតាមលទ្ធិព្រាហ្មណ៍ស្ទើរតែទាំងអស់គ្នា ទាំងប្រជាជនសោតក៏មិនមានសណ្ដាប់ធ្នាប់ជាអរិយកជាតិនៅឡើយទេ ។

មែនពិត ជនជាតិដែលជាម្ចាស់ទឹកដីនេះពីដើមគឺ មិលក្ខជាតិ មិនមែនជាអរិយកជាតិទេ ។

តែក្រោយមកពួកអរិយកជាតិ ដែលតាំងទីនៅភូមិភាគខាងជើងភ្នំហិមាល័យនោះ បានចូលមកដេញពួកមិលក្ខជាតិ រួចបានសាងទីក្រុងឈ្មោះកបិលព័ស្ដុ នៅក្នុងដងព្រៃម៉ៃសកហៅថា វជ្ជសក្កៈ នាខាងទាយត្រើយស្ទឹងរោហិណី ។

ឯត្រើយខាងអាយស្ទឹងរោហិណី ក៏មានកោលិយៈនៅនាមាត់ស្ទឹងរោហិណីនោះដែរ ។

ជនជាតិអរិយកៈ និងជាតិកោលិយៈនេះហើយ ដែលជាព្រះញាតិវង្សនៃព្រះសម្ពុទ្ធរបស់យើងនោះ ។

មុនព្រះពុទ្ធកើត និងព្រះពុទ្ធកំពុងកើតនោះ ជនជាតិទាំងនេះមិនទាន់កាន់ពុទ្ធសាសនាទេ គាត់ច្រើនជាអ្នកអនុវត្តតាមតែលទ្ធិព្រាហ្មណ៍សាសនា ហើយប្រកាន់វណ្ណៈណាស់ផង ។

ក្នុងយុគសម័យនោះ គេចាត់មនុស្សជា ៤ វណ្ណៈគឺ :

**១-វណ្ណក្សត្រ** (អ្នករដ្ឋប្បសាសនោបាយ-យុទ្ធសាស្ត្រ),

**២-វណ្ណព្រាហ្មណ៍** (អ្នកបង្ហាត់បង្រៀន និងវេជ្ជធម្មសាស្ត្រ),

**៣-វេស្សៈ** (អ្នកឧស្សាហកម្ម និងពាណិជ្ជករ),

**៤-សុទ្រ:** (អ្នកកសិករ និងកម្មករ) ។

វណ្ណៈទាំង ៤ នេះ ឆ្ងាយពីគ្នាដូចមេឃ និងដីសម័យនោះ ។ ឧទាហរណ៍ : បើពួកណាមួយដូចជាវណ្ណព្រាហ្មណ៍ទៅរួមសំរាសជាមួយនឹងវណ្ណសូទ្រ: លុះមានកូនចៅមក គេចាត់គ្នានោះថា ជនចណ្ឌាល (អ្នកអាក្រក់ថោកទាប) ។

កាន់ប្រកាន់វណ្ណៈនេះជាប់រហូតដល់មកសម័យពុទ្ធកាលជំនាន់វិឌូឌ-ក: ។ សង្គ្រាមវិឌូឌក:ជាសង្គ្រាមបំបាត់មានៈនៃការប្រកាន់វណ្ណៈ, ដូចនេះពួកសក្កៈឬសាក្យ:ក្នុងសម័យនោះវិនាសអស់ច្រើនណាស់. ឯខ្លះទៀតដែលរត់រួច ក៏កៀសខ្លួនទៅទៅឯមោរិយនគរ និងបាដលិបុត្រ ។ល។

ដោយពុទ្ធសាសនាមានធម្ម:ត្រឹមតែសមធម៌ចំពោះមនុស្សជាតិនោះទើបពួកពុទ្ធសាសនិកមានសាធារណនាមបញ្ញត្តិថា ភិក្ខុ និងភិក្ខុនី, ឧបាសក និងឧបាសិកាតែប៉ុណ្ណោះ ទោះមានវណ្ណៈជាអ្វីក៏ដោយ ។

ក្នុងបរកវសូត្រ និងវសេលសូត្រ សុត្តនិបាត ខុទ្ទកនិកាយ ព្រះពុទ្ធទ្រង់ចែងថា :

**ជាតិថទ្ធោ ធនថទ្ធោ**
**គោត្តថទ្ធោ ច យោ នរោ,**
**សញ្ញាតឹ អតិមញ្ញេតិ**
**តំ បរាភវតោ មុខំ ។**

ន ជច្ចា វសលោ ហោតិ
ន ជច្ចា ហោតិ ព្រាហ្មណោ,
កម្មុនា វសលោ ហោតិ
កម្មុនា ហោតិ ព្រាហ្មណោ ។

ជនណាប្រកាន់ពូជជាតិ បើងខ្លួនសាងទ្រព្យធនធាន អាងគោត្រត្រកូលសែស្រឡាយ ប្រមាថមើលងាយសាច់ញាតិខ្លួន និងអ្នកដទៃថា គេមានពូជជាតិជាដើម ថោកទាបមិនស្មើនឹងខ្លួន, នោះឈ្មោះថា គេកំពុងបំបែរមុខទៅរកវេណ្ឌាគឺ សេចក្ដីវិនាសហិនហោចដោយពិត ។

(តាមពិត)ដែលហៅថា : ថោកទាបមិនមែនសំដៅយកពូជជាតិជា-ដើមទេ, ហើយដែលហៅថា ប្រសើរខ្ពង់ខ្ពស់ ក៏មិនមែនសំដៅយកពូជជាតិជាដើមដែរ, ដែលហៅថា ថោកទាបនោះសំដៅយកកម្មគឺ អំពើអាក្រក់មិនបរិសុទ្ធដែលមនុស្សម្នាក់ៗធ្វើទៅតើ, ហើយដែលហៅថា ប្រសើរខ្ពង់ខ្ពស់ក៏សំដៅយកកម្មគឺ អំពើល្អបរិសុទ្ធដែលគេធ្វើនោះដែរ ។

ម្យ៉ាងទៀត សម្បីការចែកលាភឬការបរិច្ចាគទាន ក៏ពុទ្ធសាសនាឲ្យអនុវត្តតាមសមធម៌ដែរ, មិនឲ្យអនុវត្តជាបាដិបុគ្គលិកចំពោះបុគ្គលម្នាក់ៗឡើយ, គឺឲ្យអនុវត្តជាសាធារណលាភ ឬ សាធារណសង្ឃដែលហៅថាសង្ឃលាភឬសង្ឃទាននោះ ។

ព្រះពុទ្ធទ្រង់ពន្យល់ព្រះមាតាចិញ្ចឹមរបស់ព្រះអង្គក្នុងទក្ខិណាវិភង្គសុត្តវណ្ណនា មជ្ឈិមនិកាយថា :

**សំឃេ គោតមិ ទេហិ សំឃេ តេ ទិន្នេ**
**អហញ្ចេវ បូជិតោ ភវិស្សាមិ សំឃោ ចាតិ ។**

*បពិត្រព្រះមហាបជាបតិគោតមី ! សូមព្រះមេបរិច្ចាគទានជាសាធារណៈចំពោះព្រះសង្ឃចុះ កាលបើព្រះមេបានបរិច្ចាគទានជាសាធារណៈចំពោះព្រះសង្ឃហើយ ទុកជាតថាគតក្តី ព្រះសង្ឃក្តី ក៏ឈ្មោះថា ព្រះមេបានគោរពបូជាហើយដែរ ។*

*ត្បិតសាសនារបស់តថាគត រមែងឋិតទីឋិតនៅលើព្រះភិក្ខុសង្ឃ មិនមែនឋិតនៅអស់ចីរកាលលើតថាគតម្នាក់ឯងនោះទេ ។*

*( បកិណ្ណកកថាចប់ )*